ក្រសួងអប់រំ យុវជន និង កីឡា

# ១៣ ពិភពការងារ

# បញ្ឈប់ពលកម្មកុមារ

## ការពារសិទ្ធិកុមារតាមរយៈការអប់រំ_សិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយ

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អង្គការពលកម្មអន្តរជាតិ

២០០៧

## វត្ថុបំណង



យល់ច្បាស់អំពីពិភពការងារ និងផលប៉ះពាល់ទៅលើទិដ្ឋភាពផ្សេងៗគ្នានៃពលកម្មកុមារ ។

-ពង្រីកការទាក់ទងជាច្រើនជាមួយដៃគូទាំងឡាយក្នុងសង្គម ដើម្បីទាញអារម្មណ៍ឱ្យផ្តោតទៅលើពលកម្មកុមារ និងចែករំលែកគ្នានូវការទទួលខុសត្រូវ ដើម្បីលុបបំបាត់បញ្ហានេះ ។

-លើកទឹកចិត្តកិច្ចពិភាក្សាត្រីភាគីលើពលកម្មកុមារ ។



## លទ្ធផលរំពឹងទុក

-ធ្វើឱ្យមានការយល់ដឹងស៊ីជំរៅអំពីតួនាទីរបស់ផ្នែកផ្សេងៗនៃសង្គម និងបង្ហាញឱ្យឃើញថា តើផ្នែកទាំងនោះអាចចូលរួមចំណែក លុបបំបាត់ពលកម្មកុមារយ៉ាងដូចម្តេច ។

-បង្កើននូវសក្តានុពលដើម្បីបញ្ចូលសហគមន៍ និងលើកកំពស់ការយល់ដឹងព្រមទាំងប្រមូលនូវមូលនិធិឱ្យមានច្រើន ។

## ការកំណត់ពេលវេលា

បង្រៀន ៦ពេល ( ម្តងពីរពេលជាប់គ្នា ប្រសិនបើអនុវត្តគ្រប់សកម្មភាព) ។



## កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

ម៉ូឌុលនេះបន្ថែមទៅលើម៉ូឌុលទាំងឡាយ ដែលមានចំណងជើងថាអក្សរសាស្រ្ត ការស្រាវជ្រាវ និងការផ្សព្វផ្សាយ ,ការសន្ទនា និងការអង្កេតការពិភាក្សា និងឧបករណ៍សម្រាប់ផ្សព្វផ្សាយ ។ ដូច្នេះសូមអនុវត្តម៉ូឌុលខាងលើទាំងនោះមុននឹងអនុវត្តម៉ូឌុលមួយនេះ ។

សៀវភៅឈ្មោះពិភពការងារ គឺជាម៉ូឌុលមួយដែលមានសារៈសំខាន់ សម្រាប់

ជួយយុវជនឱ្យបានយល់អំពីរបៀបដែលសង្គមមានដំណើរការ របៀបដែលធាតុផ្សេងៗមានអន្តរកម្ម នៅក្នុងសង្គម ។

ប៉ុន្តែគេគួរតែរង់ចាំ រហូតដល់ពេលដែលគេទទួលបាននូវចំណេះដឹងដល់កំរិតណាមួយ និងសមត្ថភាពទាំងឡាយសិន ដើម្បីទទួលបាននូវផលកម្រៃ ចេញពីលំហាត់មួយចំនួន ។

ម៉ូឌុលដែលមានចំណងជើងស្រាវជ្រាវ និងផ្សព្វផ្សាយនឹងផ្តល់ស្ថិតិទំនាក់ទំនង រវាងដៃគូក្នុងសង្គមជាមួយនឹងរដ្ឋាភិបាលក៏ដូចជាបញ្ហាមនុស្សធម៌ និងស្ថិតលើទិដ្ឋភាពផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍន៍ ដែលជាអទិភាព ។ ម៉ូឌុលដែលមានចំណងជើងថា សន្ទនា និងអង្កេត នឹងលើកទឹកចិត្តយុវជនឱ្យមានទំនាក់ទំនងជាមួយបុគ្គលជាន់ខ្ពស់ដែលផ្សារភ្ជាប់ទៅនឹងពិភពការងារ ។

ម៉ូឌុលបង្កើតអក្សរសាស្ត្រនឹងជួយយុវជនឱ្យពង្រីកសមត្ថភាពអក្សរសាស្ត្រហើយម៉ូឌុល "ឧបករណ៍ផ្សព្វផ្សាយ" នឹងជួយពង្រីកសមត្ថភាពទំនាក់ទំនងរបស់ពួកគេ ។ ក្នុងម៉ូឌុល "ពិភាក្សា" យុវជនទាំងឡាយនឹងរៀនសម្រិតសម្រាំងការសំអាងរបស់ខ្លួនលើពលកម្មរបស់កុមារ និងបង្ហាញនូវការសំអាងរបស់ខ្លួន ដោយធ្វើយ៉ាងណាឱ្យគេជឿនៅចំពោះមុខសាធារណជន ដែលនៅក្នុងនោះប្រហែលជាមានអ្នកតំណាងពិភពនៃការងារផងដែរ ។

## ហេតុផល



អង្គការពលកម្មអន្តរជាតិ គឺជាអង្គការតែមួយគត់នៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ ដោយហេតុថា រចនាសម្ព័ន្ធរបស់ខ្លួនមិនត្រឹមតែបញ្ចូលសមាជិករដ្ឋាភិបាលទាំងឡាយទេ ប៉ុន្តែត្រូវបញ្ចូលតំណាងអង្គការនិយោជក និងកម្មករផងដែរ ។ នេះគឺជា បញ្ហារចនាសម្ព័ន្ធត្រីភាគីការងារនេះទំនាក់ទំនងពិសេសរវាងដៃគូក្នុងសង្គមទាំងឡាយក្នុងក្របខ័ណ្ឌ របស់អង្គការអន្តរជាតិ(ILO)ដែលនៅក្នុងនោះកម្មករនិយោជក និងរដ្ឋាភិបាលចូលរួមបង្កើតច្បាប់ការងារ និងការពារសិទ្ធិរបស់ពលករក្នុងទូទាំងពិភពលោក ។

ការងារត្រីភាគីមិនត្រឹមតែជាមូលដ្ឋានគ្រឹះនៃស្ថិរភាពសង្គមចំពោះវាជាគ្រឹះនៃការរីកចម្រើន និងការអភិវឌ្ឍន៍យូរអង្វែងផងដែរ ក៏ប៉ុន្តែក្នុងទស្សនៈវិស័យនេះ ការយកចិត្តទុកដាក់ពិសេសត្រូវផ្តោត ទៅលើពលកម្មកុមារ ។

អង្គការការងារអន្តរជាតិ(ILO)លើកទឹកចិត្តការងារត្រីភាគីក្នុងចំណោមសមាជិកល្អដោយលើកកំពស់ "ការសន្ទនាសង្គម" គឺជាពាក្យដែលមានន័យថា ពិភាក្សាចរចាររវាងអង្គត្រីភាគី គឺមាន រដ្ឋាភិបាល និយោជក និងសហជីព។ សកម្មភាពនេះមានឈ្មោះថា "ការសន្ទនា" សម្រាប់ឱ្យគេ ផ្លាស់ប្តូរគ្នានូវទស្សនៈ និងបទពិសោធន៍ទាំងឡាយ រវាងក្រុមផ្សេងៗ ដែលមានការយកចិត្តទុកដាក់ កាលណាក្រុមនោះព្យាយាមឈានទៅដល់ការចុះសម្រុងទៅលើស្ថានភាពណាមួយ វិស័យណាមួយ ឬ បញ្ហាណាមួយជាពិសេសបញ្ហាសេដ្ឋកិច្ច ឬសង្គមជាតិដែលបង្ហាញប្រាប់ពីទំនាក់ទំនងដៃគូក្នុងសង្គម ប៉ុន្តែក៏បានបញ្ជាក់ផងដែរថា ការសន្ទនា គឺត្រូវបានសន្មតក្នុងផលប្រយោជន៍ដ៏ល្អបំផុតរបស់សង្គម។

ម្យ៉ាងទៀតម៉ូឌុលនេះមានបំណងឆ្ពោះទៅលើកកម្ពស់"ការសន្ទនាសង្គម"រវាងពួកយុវជនមួយផ្នែក និងមួយផ្នែកទៀតរវាងរដ្ឋាភិបាល និងអង្គការពលករទាំងឡាយ និងនិយោជកនៃប្រទេសដែលគេរស់នៅ។ ផ្នែកមួយនៃដំណើរការអប់រំតម្រូវឱ្យយល់ អំពីរបៀបដែលពិភពការងារមានដំណើរការ និងអំពីរបៀបដែលយើងចូលរួមចំណែកទទួលខុសត្រូវទាំងអស់គ្នាចំពោះអ្វីដែលកើតឡើងនៅក្នុងសង្គមរបស់យើង។ ប៉ុន្តែនៅពេលសរសេរម៉ូឌុលទាំងនេះ យើងទាំងអស់គ្នាមានមនសិការជានិច្ចថា ប្រព័ន្ធនៃរដ្ឋាភិបាល, ភាពជាដៃគូសង្គម,តំណាងពលករ និងនិយោជកមានការប្រែប្រួលដ៏ខ្លាំងក្លា ពីប្រទេសមួយទៅប្រទេសមួយទៀត។ រចនាសម្ព័ន្ធ និងប្រព័ន្ធដែលត្រូវបានគូសបញ្ជាក់ក្នុងសៀវភៅនេះ មិនអាចស៊ីគ្នានឹងរចនាសម្ព័ន្ធ ឬប្រព័ន្ធរបស់ប្រទេសអ្នកផ្ទាល់,ប៉ុន្តែរឿង មិនសមស្របគ្នានេះ មិនអាចមានឥទ្ធិពលក្នុងការអនុវត្តឡើយ។ លោកអ្នកត្រូវតែសម្របសម្រួលចំណុចត្រង់នេះខ្លះ ត្រង់នោះខ្លះ ដើម្បីអនុលោមទៅតាមគំរូត្រីភាគី។

ហេតុដូច្នេះ,លោកអ្នកត្រូវតែយកចិត្តទុកដាក់ទៅតាមគំរូត្រីភាគីក្នុងឋានៈជាអ្នកលើកកំពស់ប្រជាធិបតេយ្យរបស់សង្គម។ ម៉ូឌុលនេះអាចជួយអ្នកឱ្យការយល់ដឹងផ្ទាល់ នូវគំរូត្រីភាគី ហើយអង្គការពលកម្មអន្តរជាតិ (ILO) អាចផ្តល់ពតិមានបន្ថែមទៀតដល់លោកអ្នក។

ការលើកឡើងប្រកបដោយមនសិការ ចំពោះពលកម្មរបស់កុមារក្នុងបំណងលុបបំបាត់បញ្ហានេះ គឺជាដំណើរការរបស់ពិភពលោក។ ដូច្នេះគេបញ្ចូល អ្នកសំដែងតួជាច្រើន

ចូលទៅក្នុងសហគមន៏ធំទូលាយពិសេស អ្នកដែលអាចធ្វើឱ្យស្ថានភាពមានការប្រែប្រួល បានឆាប់រហ័សបំផុត : រដ្ឋាភិបាល ពលករ (សហជីព) និងនិយោជិក។

ឱ្យអំណាចទៅយុវជនមិនគ្រប់គ្រាន់ទេដោយសារឧបករណ៏ប្រើប្រាស់ និងការផ្សព្ផ្សាយចំណេះដឹងរបស់គេ,យើងត្រូវការដាក់បញ្ហាពលកម្មរបស់កុមារនៅក្នុងបរិបទមួយដ៏ធំទូលាយ ហើយលើកទឹកចិត្តយុវជនទាំងឡាយឱ្យរៀនសូត្របន្ថែមទៀតអំពីរបៀបដែលអ្វីៗមានដំណើរការ ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ច និងក្នុងសង្គមជាទូទៅ។ រឿងនេះនឹងជួយយុវជនឱ្យកំណត់ច្បាស់នូវចំណុចគោល ក្នុងសកម្មភាពរៀនយល់ដឹង របស់គេ និងជួយពួកគេឱ្យប្រឹងប្រែងបង្កើន មនសិការ និងសកម្មភាព។

ប្រសិនបើពលកម្មរបស់កុមារកើតមានក្នុងប្រទេសរបស់លោកអ្នក តួនាទីរបស់រដ្ឋាភិបាល និងដៃគូក្នុងសង្គម ត្រូវតែធ្វើការជាមួយគ្នា ដើម្បីរំដោះកុមារ ពីទីកន្លែងពលកម្ម និងត្រូវយកចិត្តទុកដាក់ដល់ពួកគេ,បង្រៀនគេ និងយកចិត្តទុកដាក់ដល់សុខុមាលភាពរបស់គេ សូមអ្នកស្វែងយល់ថា តើក្រុមទាំងបី រៀបកម្មវិធីអប់រំយុវជនឬទេ ឧទាហរណ៏, ក្រុមសហជីពខ្លះ ស្នើឡើងនូវកម្មវិធីសម្រាប់និស្សិត ឬសម្រាប់ក្រុមយុវជន ហើយផ្តល់ដល់យុវជននូវ ព័តិមានស្តីពីសិទ្ធិ កន្លែងធ្វើការ អំណោយផលពីសហជីព និងប្រភេទសេវាកម្មសម្រាប់យុវជន។ អ្នកនឹងមានលទ្ធភាពអញ្ជើញតំណាងនៃក្រុមការងារ រួមការងារមកពិភាក្សាជាមួយក្រុមរបស់អ្នក។

## ការរៀបចំ



*ជំនួយពីខាងក្រៅ*

មុននឹងអនុវត្តម៉ូឌុលនេះ គប្បីធ្វើការស្រាវជ្រាវដំបូងជាមូលដ្ឋានលើក្រុមទាំងបីដែលបង្កើតរចនាសម្ព័ន្ធត្រីភាគី រដ្ឋាភិបាល អង្គការពលកម្មទាំងឡាយ (សហជីព) និងអង្គការនិយោជក និងគប្បីមើលឱ្យឃើញថា តើប្រព័ន្ធការងាររបស់ប្រទេសលោកអ្នកដំណើរការដូចម្ដេច។

សូមកុំភ្លេចថា បើសិនលោកអ្នកស្ថិតនៅក្នុងបរិបទនៃការអប់រំក្នុងប្រព័ន្ធបុគ្គលិកបង្រៀនអាចរួមចំណែកមួយនៃអង្គការរបស់គ្រូបង្រៀន។ សូមទាក់ទងផ្ទាល់តំណាងរបស់សាលារៀន ដើម្បីដឹងអំពីរបៀបដែលអង្គការគ្រូបង្រៀន (សមាគម)អាចមានដំណើរការ ដើម្បីវិស័យអ្វីខ្លះដែលមានផលប្រយោជន៍រួម ដែលអាចទទួលយកបាន ហើយដើម្បីដឹងថាតើសហជីពអាចមកពិភាក្សា ជាមួយក្រុមអ្នកឬទេ។



## អ្វីដែលអ្នកត្រូវការ



- ✓ ក្រដាស និងស្លាបប៉ាក់កា ឬខ្មៅដៃ
- ✓ ក្ដារខៀនខ្មៅ/សឬផ្សេងទៀត
- ✓ ឧបករណ៍បញ្ចាំងស្លាយ
- ✓ ការប្រើប្រាស់ទូរស័ព្ទ

## ការចាប់ផ្ដើម



ជោគជ័យរបស់ម៉ូឌុលអាស្រ័យដោយសមាជិកក្រុម និងផលប្រយោជន៍របស់គេ ក៏ដូចជាពេលទំនេររបស់តំណាងទាំងបី នៃ"ពិភពការងារទាំងបី"។ ក្រុមត្រូវពិចារណារកហេតុផលដែលត្រូវទៅទាក់ទងក្រុមទាំងនោះ និងមានគោលបំណង និងទិសដៅអ្វីខ្លះ។ គេក៏ត្រូវប្រមើលផងដែរ នូវលទ្ធផលប្រាស្រ័យទាក់ទងមួយ ឬច្រើនជាងក្រុមទាំងនោះ។ ជាការជាក់ស្ដែង ក្រុមអ្នកត្រូវប្រមើលមើលលទ្ធផល ទាក់ទងក្រុមនីមួយៗដើរតួផ្សេងៗគ្នាក្នុង បរិបទសង្គមសេដ្ឋកិច្ច និងរ៉ាប់រងការទទួលខុសត្រូវផ្សេងៗគ្នា។

ដូច្នេះគ្រប់ក្រុមទាំងអស់ជាការប្រសើរជាង សូមជំរុញក្រុមរបស់លោកអ្នកឱ្យរៀបចំចំណុចផ្សេងៗដែលត្រូវទៅទាក់ទង។ លើកទឹកចិត្តក្រុមទាំងនោះឱ្យសរសេរ ឬនិយាយទូរស័ព្ទទៅកាន់ទីកន្លែងការិយាល័យក្នុងស្រុកនៃអង្គការកម្មករ និយោជកសកម្មភាព ការិយាល័យព័ត៌មានរដ្ឋាភិបាល។

សកម្មភាពនេះនឹងផ្ដល់ដល់ពួកគេនូវបទពិសោធន៍ល្អមួយ។ លិខិតនីមួយៗត្រូវតែតាមដានបញ្ជាក់តាមរយៈទូរស័ព្ទ យើងអាចបង្កើតក្រុមតូចៗដើម្បីឱ្យក្រុមនីមួយៗ អាចទាក់ទងផ្ទាល់ជាមួយអង្គភាពមួយដាច់ដោយឡែកពីគ្នា : រដ្ឋាភិបាល អង្គការ នានា របស់ពលករ ឬនិយោជក។ ការងាររបៀបនេះអាចបង្កើតបាននូវវិធីមួយដ៏ប្រសើរ ដោយហេតុថាវិធីនេះ អាចឈានទៅដល់ការពិភាក្សាដ៏មាន ប្រយោជន៍ផ្ទាល់ជាមួយក្រុម។

*ការរៀបចំក្រុម*



សម្រាប់សកម្មភាពដំបូងទាំងពីរទៅតាមទំហំនៃក្រុម,គេអាចមើលឃើញប្រសិទ្ធភាពច្រើន ដែលស្តែងចេញពីការបង្កើតក្រុមជាបី ដែលនឹងធ្វើការដាច់ដោយឡែកពីគ្នា ជូនកាលជាមួយតំណាងនៃរដ្ឋាភិបាល ជូនកាលជាមួយអង្គការ ពលករ ឬនិយោជក។ យន្តការត្រូវតែមានលក្ខណៈប្រជាធិបតេយ្យ, ឧទាហរណ៍ ដោយយកឈ្មោះតាមការផ្សងសំណាងចាប់ឆ្នោត។

ប្រសិនបើក្រុមធំហួសពេក ចូរបង្កើតក្រុមតូចៗដែលមានមនុស្សបី ឬ បួននាក់ នៅក្នុងក្រុមទាំងបីខាងលើ ដើម្បីធានាការសន្ទនា និងការចូលរួមពីគ្រប់មជ្ឈដ្ឋាន។ ឧទាហរណ៍ក្រុមរបស់រដ្ឋាភិបាលម្នាក់ៗ ត្រូវចាត់ចែងការងារ និងទទួលខុសត្រូវចំពោះក្រុមរបស់ខ្លួន។ អាចចែកជាទីស្តីការរដ្ឋមន្ត្រីជាច្រើន, អ្វីដែលទាក់ទងនឹងនិយោជក សូមស្នើសុំដល់ក្រុមទាំងឡាយឱ្យជ្រើសរើសតំបន់ណាមួយ ឬអង្គការណាមួយដែលត្រូវធ្វើការស្រាវជ្រាវសម្រាប់កម្មករ ក្រុមទាំងឡាយ អាចជ្រើសរើសអង្គការសហជីពផ្សេងៗគ្នា។ អ្វីដែលសំខាន់ គឺបុគ្គល។

## សកម្មភាពមួយ : ការស្រាវជ្រាវ

*ពេលប្រជុំធម្មតា១ពេល និងពេលប្រជុំទ្វេ ដោយពន្លើសពេលបន្តិចបន្តួចដើម្បីបញ្ចប់ការស្រាវជ្រាវ*

ដំណាក់ទី១ តម្រូវឱ្យមើលឃើញច្បាស់លាស់ ដែលស្ថាប័ននីមួយៗនៃត្រីភាគីបានធ្វើ និងរបៀបដែលគេធ្វើចលនា។ ទៅតាមប្រទេសនីមួយៗក្រសួង និងទីស្តីការត្រូវបានរៀបចំផ្សេងៗគ្នា។

អង្គការពលករ និងនិយោជក ក៏មានរៀបចំដំណើរការដូចគ្នាដែរ។ តើពួកគេមានទំនាក់ទំនងជាក់លាក់អ្វីខ្លះ ជាមួយនឹងពលកម្មកុមារ ហើយពួកគេអាចជួយកុមារដូចម្តេច?

គឺមានសារៈសំខាន់ណាស់សម្រាប់អនាគតនៃការសិក្សា និងអាជីពការងាររបស់យុវជន ក្នុងការរៀនពីរបៀប និងទីកន្លែងដែលត្រូវស្វែងរកព័ត៌មានដែលទាក់ទង និងរក្សាលំដាប់លំដោយនូវលទ្ធផលនៃការវិភាគ និងបង្ហាញនូវព័ត៌មានប្រកបដោយប្រសិទ្ធភាពសម្រាប់គោលបំណងរបស់ពួកគេ។

## កំណត់សម្គាល់សំរាប់អ្នកប្រើប្រាស់



យើងសូមឱ្យអ្នកស្វែងរកព័ត៌មាននៅក្នុងម៉ូឌុលស្រាវជ្រាវនិងព័ត៌មាន ក្នុងបំណងរៀបចំការងារនេះ។ ម៉ូឌុលនេះសម្រាប់រំលឹកអំពីរបៀបធ្វើការស្រាវជ្រាវអំពីប្រធានបទពិសេស។ លោកអ្នកអាចប្រើប្រាស់បណ្ណាល័យក្នុងស្រុក ឬ អ៊ីនធើណែតពីព្រោះវាមានប្រយោជន៍ណាស់ដើម្បីធ្វើឱ្យបានសម្រេចការស្រាវជ្រាវ។ បើពុំនោះទេការស្រាវជ្រាវ អាចធ្វើឡើងដោយសំភាសន៍បុគ្គលផ្ទាល់ដោយសំណេរ ឬដោយផ្ទាល់ជាមួយគេតាមរយៈទូរស័ព្ទ។ ជានិច្ចកាលក្រុមទាំងឡាយអាចធ្វើការជាមួយនឹងធនធានដែលមានស្រាប់។ សូមកុំភ្លេចថារដ្ឋាភិបាលអាចមានផ្នែកព័ត៌មានដ៏ល្អប្រពៃ ហើយអង្គការនិយោជក និងពលករប្រភពព័ត៌មានល្អៗសំរាប់ឱ្យសាធារណជនប្រើប្រាស់បាន។

*ការរៀបចំភារកិច្ច*

កិច្ចការតម្រូវឱ្យក្រុមធ្វើការស្រាវជ្រាវទៅលើសហគមន៍ ការបែងចែកការងារ និងធ្វើការរៀបចំការងារដែលលោកអ្នកបានប្រគល់ឱ្យក្រុមការងារ។ ចំនួនការងារល្អៗដែលអាចប្រគល់ឱ្យក្រុមបាន ប៉ុន្តែជាការសំខាន់គឺការងារទាំងនោះមានប្រយោជន៍ និងមានអន្តរកម្ម ឧទាហរណ៍ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំមានតួនាទីអ្វីខ្លះក្នុងយុទ្ធនាការលុបបំបាត់ពលកម្មរបស់កុមារ? តើសហព័ន្ធ សហជីពជាតិធ្វើអ្វីចំពោះការងារនេះ? តើមានឃ្លាំងលក់ទំនិញដែលមាន សីលធម៌ និងតម្លៃសមរម្យក្នុងតំបន់របស់លោកអ្នកឬទេ? តើឃ្លាំងទំនិញមានដំណើរការយ៉ាងដូចម្តេច? ក្រុមទាំងអស់ត្រូវពន្យល់ដោយបង្ហាញហេតុផលនូវការស្រាវជ្រាវរបស់ខ្លួនដោយប្រើប្រាស់ហេតុការណ៍ និងតួលេខ ដែលគេរកឃើញនៅក្នុងឯកសារ។ ការស្វែងរកឯកសារទាំងនេះ គឺជាផ្នែកមួយនៃការងាររបស់ខ្លួន។ នេះជាសំណួរមួយចំនួនក្នុងចំណោមសំណួរដែលក្រុមការងារទាំងអស់ត្រូវយកចិត្តទុកដាក់:

តើអង្គការទាំងឡាយធ្វើអ្វីខ្លះចំពោះពលកម្មរបស់កុមារ?

- តើគេមានជំហរដូចម្តេចចំពោះការងាររបស់កុមារ? តើគេត្រូវដាក់ទោសទណ្ឌ ឬត្រាប្រណី ចំពោះពលកម្មរបស់កុមារ? លុបបំបាត់ពលកម្មរបស់កុមារ?
- តើគេរួមចំណែកឬទេចំពោះការទទួលខុសត្រូវនៅក្នុងយុទ្ធនាការពិភពលោក?

- តើគេបានដាក់វិធានការណាខ្លះ?
- តើគេចូលរួមចំណែកឬទេ ចំពោះគម្រោងស្តីពីពលកម្មកុមារនៅក្នុងប្រទេសរបស់ខ្លួនផ្ទាល់ ឬនៅប្រទេសដទៃទៀត។
- តើអង្គការទាំងនេះបានរួមចំណែកក្នុងបណ្តាញតំបន់ ឬអន្តរជាតិដ៏ធំទូលាយឬទេ?
- តើបណ្តាញនេះមានដំណើរការយ៉ាងដូចម្តេច?
និងធ្វើដូចម្តេចដើម្បីប្រយុទ្ធប្រឆាំងនឹងពលកម្មរបស់កុមារ?
- តើវិស័យអ្វីដែលអង្គការទាំងនេះមានសកម្មភាពខ្សោយ ឬខ្លាំង?
- តើមានវិធានការបើកចំហដល់កម្រិតណាសម្រាប់ទទួលការស្រាវជ្រាវអំពីពលកម្មរបស់កុមារ?

យុវជនត្រូវការជំនួយនិងការគាំទ្រសម្រាប់ការទំនាក់ទំនងផ្សេងៗ។ រឿងទាំងនោះហាក់ ដូចជាធ្វើឱ្យមានការចាប់អារម្មណ៍ត្រូវតែសរសេរ ឬទូរស័ព្ទទៅទីស្តីការរដ្ឋាភិបាល ឬទីចាត់ការក្រុមហ៊ុន ដ៏ធំណាមួយ ឬសហជីពណាមួយ។

## ដឹកនាំការស្រាវជ្រាវ

វាជាការសំខាន់ដែលលោកអ្នកធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមនីមួយៗក្នុងពេលស្រាវជ្រាវរបស់គេ ហើយវាជាការសំខាន់ដែលអ្នកត្រូវត្រៀមជួយគេ និងគាំទ្រនៅពេលគេត្រូវការ ឬនៅពេលដែលអ្នកត្រូវការរឿងនោះសួរគេ ឧទាហរណ៍ប្រសិនបើអ្នកបាន គេស្នើឱ្យផ្តល់ជំនួយសម្រាប់ការចូលនិវត្តន៍នេះ សូមគ្រូបង្រៀន ឬឪពុក ម្តាយមេត្តាផ្តល់ជំនួយដល់ពួកគេទៅ។ នេះជាការអនុវត្តការងារមួយដែលតម្រូវលោកអ្នក ធ្វើជាអ្នកគ្រប់គ្រងស្ថានភាព ព្រោះការងារនោះនាំមកនូវការខំប្រឹងប្រែងយ៉ាងខ្លាំង និងការងារដ៏ច្រើនសន្ធឹកសន្ធាប់លោកអ្នកនឹងត្រូវការថាមពលទាំងអស់របស់អ្នក និងសេចក្តីសប្បាយរីករាយផ្ទាល់របស់អ្នកចំពោះអ្វីដែលកំពុងតែធ្វើ។ សូមពន្យល់របៀបដែលជំនួយនេះមានប្រយោជន៍ក្នុងពេលចុងបញ្ចប់នៃការងារ និងរបៀបដែលជំនួយនោះជាកិច្ចសន្យាម្យ៉ាងបន្ថែមទៀត។

ក្នុងបំណងជួយលោកអ្នកក្នុងដំណើរការស្រាវជ្រាវលោកអ្នកនឹង

ឃើញសេចក្តីសង្ខេបនៃអង្គភាពផ្សេងៗ ទីស្តីការការិយាល័យផ្សេងៗ ដែលត្រូវធ្វើការទំនាក់ទំនងក្នុងក្របខ័ណ្ឌនៃពលកម្ម របស់កុមារគ្រប់ប្រភេទដូចជា :

រដ្ឋាភិបាល ពលករ ឬនិយោជកជាដើម ឈ្មោះរបស់ក្រសួងទីស្តីការអាចប្រែប្រួលទៅតាមប្រទេស ។

*រដ្ឋាភិបាល ថ្នាក់ជាតិ*

**ទីស្តីការរដ្ឋមន្ត្រីក្រសួងការបរទេស** គឺជាផ្នែកសំខាន់នៃសកម្មភាព និងការទំនាក់ទំនងខាងក្រៅរបស់រដ្ឋាភិបាល ។ តាមធម្មតាក្នុងបណ្តាប្រទេសឧស្សាហកម្ម ទីស្តីការទាំងនេះតាមធម្មតាគឺជាអ្នកទទួលខុសត្រូវកម្មវិធីសកម្មភាពសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ទោះបីយ៉ាងណាក៏ដោយ ទីស្តីការ ក្រសួង មន្ទីរទាំងនេះ គឺជាកន្លែងដែលត្រូវប្រាស្រ័យទាក់ទងមុនគេបង្អស់ដើម្បីមើលឃើញនូវអ្វីដែលរដ្ឋាភិបាលចាត់ការជាក់ស្តែងក្នុងការប្រយុទ្ធប្រឆាំងនឹងពលកម្មរបស់កុមារក្នុងពិភពលោក ។

ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ទីស្តីការទាំងនេះគឺ ជាអ្នកទទួលខុសត្រូវយ៉ាងខ្លាំងក្នុងការបែងចែកជំនួយសម្រាប់អភិវឌ្ឍ ។

## រដ្ឋាភិបាលថ្នាក់កណ្តាល

### *ក្រសួងការបរទេស*

ក្រសួងនេះត្រូវធ្វើការទំនាក់ទំនងដើម្បីឱ្យយុវជនចាប់យកចំណេះដឹងអំពីសិទ្ធិរបស់គេនៅកន្លែងធ្វើការ ។ តើគេមានវិធានការការពារខ្លួនដូចម្តេច ? តើយន្តការអ្វីខ្លះដែលធានារ៉ាប់រងការគោរពសិទ្ធិរបស់គេពីសំណាក់និយោជក? តើមានអ្វីកើតឡើងប្រសិនបើសិទ្ធិទាំងនេះមិនត្រូវបានគោរព? តើគេមានជម្រើសបែបណា? តើអាយុប៉ុន្មានអាចទទួលបំរើការងារអប្បបរិមាក្នុងកិរិតថ្នាក់ជាតិ?



### *ក្រសួងការងារ*

ជាការសំខាន់ដែលពួកយុវជនដឹងថារដ្ឋាភិបាលការពារ និងឧបត្ថម្ភតម្រូវការសង្គមដល់កិរិតណានោះ ។ ប្រព័ន្ធដែលគ្រប់គ្រងដោយរដ្ឋាភិបាលរបៀបណាដែលជាលេសនៅពេលគេទទួលឥទ្ធិពលអាក្រក់ពីភាពក្រីក្រនោះ ។

តើប្រព័ន្ធសុខមាលភាពត្រូវបានគ្រប់គ្រង និងរៀបចំដូចម្តេចសម្រាប់ប្រជាជន? ប្រាក់បំណាច់សម្រាប់គ្រួសារ ប្រាក់បំណាច់សម្រាប់ឈប់សំរាក អាហារដ្ឋានសម្រាប់សិស្ស ការឧបត្ថម្ភអ្នកខ្វះការងារធ្វើ ត្រូវបានគេចាត់ចែងរៀបចំឬទេ? តើរដ្ឋាភិបាលធ្វើអ្វីខ្លះដើម្បីជួយជនក្រីក្រក្នុងបំណងលើកកំពស់ស្ថានភាពរបស់ពួកគេឱ្យប្រសើរឡើងតាមរយៈ ការងារ ការអប់រំ និងលំនៅស្ថានផ្ទះសម្បែង ។ល ។ តើសន្តិសុខសង្គមមានទ្រង់ទ្រាយច្បាស់លាស់ឬទេ? ក្នុងប្រទេសរបស់លោកអ្នក ។



*ក្រសួងសុខមាលភាពសង្គម/កុមារ* ប្រការសំខាន់សម្រាប់ជនវ័យក្មេងគឺត្រូវស្វែងយល់ឱ្យដឹងថា តើការការពារសង្គមដែលរដ្ឋាភិបាលផ្តល់ឱ្យពួកគេទាំងឡាយដែលកំពុងត្រូវការសង្គ្រោះនេះមានកំរិតប៉ុនណា? តើស្ថានភាពក្រីក្រត្រូវរដ្ឋាភិបាលដោះស្រាយបានដូចម្តេច ជាពិសេសនៅពេលដែលកុមារត្រូវទទួលរងផលប៉ះពាល់?



តើគេត្រូវចាត់ចែងរៀបចំប្រព័ន្ធសុខុមាលភាពសង្គម និងធានាឱ្យប្រជាពលរដ្ឋមានលទ្ធភាពទទួលវាបានដោយរបៀបណា?

តើវាត្រូវធ្វើទៅតាមរូបភាពអ្វី ឧទាហរណ៍ដូចជា តាមរូបភាពប្រាក់ឧបត្ថម្ភកុមារ,ផលកម្រៃដល់ការខ្វះការងារធ្វើ,អាហារតាមសាលារៀន? តើរដ្ឋាភិបាលព្យាយាមជួយដល់ប្រជាជន ដែលត្រូវការសង្គ្រោះនេះ តាមការកែលំអស្ថានភាពបានដោយវិធីណា ដូចជាតាមរយៈការបង្កើនឱ្យមានការងារធ្វើ,ការអប់រំ ការដោះស្រាយទីជម្រក ។ល ។?



តើមានទម្រង់នៃបណ្តាញ សុខុមាលភាពសង្គមបែបណាមួយនៅក្នុងប្រទេសរបស់អ្នកដែរឬទេ ឬក៏ត្រូវទុកឱ្យប្រជាជនទាំងឡាយត្រូវ ការពារវ៉ាប់រងដោយខ្លួនឯងផ្ទាល់?



ក្រសួងអប់រំដោយប្រៀបធៀបទំនាក់ទំនងពតិមានរវាងទីស្តីការក្រសួងការងារ និងក្រសួងអប់រំ,ពួកយុវជននឹងដឹងពីអាយុអប្បបរមានៃកាតព្វកិច្ចសិក្សាក្នុងប្រទេសរបស់ខ្លួន ។ ទំនាក់ទំនងគ្នាទៅវិញទៅមករវាងការអប់រំនិងអាយុស្របច្បាប់ដែលអាចទទួលការងារបាននៃពលកម្មរបស់កុមារ ។

យុវជនត្រូវស្រាវជ្រាវហេតុផលនោះដោយខ្លួនឯងផ្ទាល់ ។ ផ្នែកណាមួយ

នៃការស្រាវជ្រាវស្របគ្នាអាចពាក់ព័ន្ធនឹងកតិកាសញ្ញា លេខ១៣៨ របស់អង្គការពលកម្មកុមារអន្តរជាតិ(ILO)ស្តីអំពីអាយុអប្បបរមាដែលអាចទទួលការងារ។

នេះគឺជាកាតិកាសញ្ញាសំខាន់បំផុតសម្រាប់ធ្វើយុទ្ធនាការពិភពលោក ដើម្បីលុបបំបាត់ពលកម្មរបស់កុមារ។ ហេតុអ្វី? សូមលើកទឹកចិត្តក្រុមឱ្យស្រាវជ្រាវហេតុផលនៃការលុបបំបាត់ការងាររបស់កុមារនេះ។ ការអប់រំមិនតម្រូវឱ្យបង់ថ្លៃទេឬនៅក្នុងប្រទេសអ្នក?

*ក្រសួងឧស្សាហកម្មពាណិជ្ជកម្មក្រសួងនេះគឺជាផ្នែកមួយ* ដ៏សំខាន់សម្រាប់ឃ្លាំមើលរបៀបដែលផលិតកម្ម និងសេវាកម្មប្រព្រឹត្តទៅក្នុងលក្ខខណ្ឌ ដែលច្បាប់ការងារត្រូវបានការពារ និងគោរពលក្ខខណ្ឌនេះត្រូវគេអនុវត្តមិនត្រឹមតែចំពោះអ្វីដែលកើតឡើងនៅ ក្នុងប្រទេសនោះទេ ក៏ប៉ុន្តែចំពោះទំនិញ និងសេវាកម្មនាំចូលក្នុងប្រទេសផងដែរ។ តើរដ្ឋាភិបាលត្រូវធ្វើអ្វីខ្លះ? ដើម្បីត្រួតពិនិត្យទំនិញនាំចូលត្រូវបានផលិត ឬដាំដោយគ្មានប្រើប្រាស់ពលកម្មកុមារ និងក្នុងល័ក្ខខណ្ឌដែលគោរពច្បាប់ការងារអន្តរជាតិ។ ការស្រាវជ្រាវក្នុងផ្នែកនេះត្រូវគ្របដណ្តប់ផងដែរលើច្បាប់បើកបរ និងសីលធម៌ ក្នុងការងារ និងការប្រឹងប្រែងនៅក្នុងតំបន់នានាដូចជា ក្របខ័ណ្ឌ UE,NAFTA, ASEAN, MERCOSUR, SADC ។ល។

## អាជ្ញាធរមូលដ្ឋាន



ក្រុមទាំងឡាយត្រូវទាក់ទងអាជ្ញាធរក្នុងស្រុកផងដែរ ដើម្បីរកឱ្យឃើញថា តើអ្នកនយោបាយក្នុងស្រុកមានមនសិការចំពោះបញ្ហាពលកម្មរបស់កុមារ និង ការជំពាក់ទាក់ទងរបស់គេចំពោះម្ចាស់ឆ្នោតឬទេ?។ ម្យ៉ាងទៀត តើអំពើណាដែលគេអាចទទួលធ្វើដើម្បីរួមវិភាគទានដល់យុទ្ធនាការពិភពលោក?

សូមលោកអ្នកកុំភ្លេចថា គេមានទីប្រឹក្សា និងអ្នកនយោបាយក្នុងស្រុកដែលតំណាងឱ្យផលប្រយោជន៍ផ្សេងៗស្របតាមរចនាសម្ព័ន្ធនៃរដ្ឋាភិបាលដូចជា ការងារ ការប្រើប្រាស់ពលករ ឧស្សាហកម្ម ពាណិជ្ជកម្ម សន្តិសុខ សង្គម អប់រំ និងបញ្ហាអន្តរជាតិ។

ឧទាហរណ៍នៅក្នុងសហគមន៍អឺរ៉ុប(UE),រដ្ឋអំណាចក្នុងស្រុកចូលរួមចំណែកនៃបណ្តាញមួយនៅតាមភូមិភាគដែលទទួលផលចំណេញពីរចនាសម្ព័ន្ធដែលផ្តល់ផលប្រយោជន៍រួម។ ដើម្បីឱ្យយុទ្ធនាការពិភពលោក សម្រេចនូវគោលបំណងរបស់ខ្លួនក្នុងការលុបបំបាត់ពលកម្មរបស់

កុមារកិច្ចសន្យា នយោបាយ ត្រូវបានផ្សាយចេញទៅគ្រប់កម្រិតមជ្ឈដ្ឋាន និងគ្រប់លំដាប់ថ្នាក់។ យុវជនត្រូវធ្វើការជាបណ្ដើរៗ ជាមួយនឹងម៉ូឌុលទាំងនេះក្នុងប្រទេសផ្សេងៗ សហគមន៍មានការចូលរួមកាន់តែខ្លាំង និងអ្នកនយោបាយគ្រប់កម្រិតនឹងចាប់ផ្ដើមកត់សំគាល់សកម្មភាព ដែលមានកាន់តែច្រើនឡើងក្នុងក្របខ័ណ្ឌនៃពលកម្មរបស់កុមារ។

ក្រៅពីការទាក់ទងជាមួយគ្រប់ផ្នែកនៃរដ្ឋាភិបាលមជ្ឈការ និងក្នុងស្រុក និងអាជ្ញាធរនៅតាមមូលដ្ឋាន សូមជំរុញក្រុមឱ្យក្លាហាន ហ៊ានទាក់ទងអ្នកនយោបាយគ្រប់និន្នាការ,ដូចជា :

- នាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីរបស់គាត់
- ប្រធានាធិបតី អនុប្រធានាធិបតី និងខុទ្ទកាល័យរបស់គាត់
- មេគណៈបក្សនយោបាយថ្នាក់កណ្ដាល និងថ្នាក់តំបន់
- មេឃុំ
- អ្នកនយោបាយដែលល្បីល្បាញ និងជាទីគោរព ទោះបីគាត់មិនមានតំណែងក្នុងរដ្ឋាភិបាលក៏ដោយសោះ។
- អ្នកនយោបាយដែលយកចិត្តទុកដាក់ជាពិសេសចំពោះបញ្ហាអភិវឌ្ឍន៍ ចំពោះបញ្ហាសង្គម ឬបញ្ហាមនុស្សធម៌
- អ្នកនយោបាយវ័យក្មេង

*និយោជក*



និយោជក,អង្គការ និងសហគមន៍ទាំងឡាយដែលជាតំណាងមានតួនាទីមិនច្បាស់លាស់នៅក្នុងយុទ្ធនាការពិភពលោកដើម្បីលុបបំបាត់ពលកម្មកុមារ។ ពលកម្មកុមារកើតមានលើកុមារដែលធ្វើការងារជាញឹកញាប់ក្នុងលក្ខខណ្ឌដែលមិនអាចអនុគ្រោះបាន។

ប្រសិនបើកុមារធ្វើពលកម្ម លោកអ្នកអាចទុកចិត្ត និងប្រាកដថា ភាគច្រើនគេមិនធ្វើដើម្បីពួកគេទេ និងមិនមានគំនិតផ្ដួចផ្ដើមបង្កើតសង្គមផ្ទាល់របស់គេទេ គេធ្វើពលកម្មពីព្រោះក្រុមហ៊ុន និងបុគ្គលជួលពួកគេជា

កម្មករធ្វើការ។ គេអាចនិយាយម្យ៉ាងទៀតថា និយោជកជួលកុមារ និងបង្កើតការងារឱ្យកុមារ។

ប៉ុន្តែកុមារជាច្រើនធ្វើការបម្រើឱ្យកម្មសិទ្ធិតូចៗនៃគ្រួសារ ដូចជា កសិដ្ឋានជាដើម គេធ្វើពលកម្មដើម្បី ឪពុកម្តាយរបស់គេ ឬដើម្បីសមាជិកផ្សេងទៀតនៃគ្រួសារគេ។ ពិសេសពលកម្មកុមារក្នុងផ្នែកកសិកម្មគឺជាការពិត។ ជួនកាលនិយោជកជួលកុមារដោយគ្មានសតិសម្បជញ្ញៈទទួលខុសត្រូវលើផលិតកម្ម។ និយោជក ក្នុងពិភពលោកទាំងមូលមានការទទួលខុសត្រូវ ផ្នែកសង្គមចំពោះពលកររបស់ខ្លួន រដ្ឋាភិបាល អតិថិជន អ្នកប្រើប្រាស់ និងជាទូទៅសហគមន៍។

- ឧទាហរណ៍សម្រាប់រៀនសូត្រមួយ ដែលលោកអ្នកអាចជូនដល់ក្រុមគឺជាឧទាហរណ៍របស់សមាគមពហុជាតិ។ តាមលំដាប់លំដោយនៃការបញ្ចូលសេដ្ឋកិច្ចទៅក្នុងសេដ្ឋកិច្ចពិភពលោក ឬតំបន់នោះសមាគមមានការងាយស្រួលក្នុងការពង្រីក និងធ្វើពលកម្មរបស់គេដោយទ្រង់ទ្រាយផ្នែកៗ។
- សមាគមអ្នកលក់ដូចជា លក់សម្ភារកីឡាជាដើម អាចពឹងផ្អែកអ្នកផលិតថោកៗនៅលើពិភពលោក និងពង្រីកការទាក់ទងផ្ទាល់នឹងក្រុមហ៊ុនដឹកជញ្ជូនដែលថោកៗ ហើយអាចប្រគល់ផលិតផល ច្រើនបែបយ៉ាងដល់អ្នកចែកចាយ និងដល់អ្នកលក់បន្តជុំវិញពិភពលោក។
- ម្យ៉ាងទៀតក្រុមទាំងនេះអាចបញ្ចូលគណនេយ្យរបស់ក្រុមហ៊ុនខ្លួនទៅក្នុងប្រទេសមួយ និងពង្រីកការទំនាក់ទំនងជាសាធារណៈ និងធ្វើប្រតិបត្តិការស្វែងរកទីផ្សារក្នុងប្រទេសមួយទៀត។
- តាមការជាក់ស្តែងក្នុងបច្ចុប្បន្ន ទីស្នាក់ការនៃក្រុមហ៊ុនពហុជាតិណាមួយនឹងអាចមានការិយាល័យដ៏តូចមួយដែលគ្រប់គ្រងកិច្ចប្រតិបត្តិការផ្សេងៗ ក្នុងបណ្តាប្រទេសនៃពិភពលោកទាំងមូល។

*និយោជក*



តាមការជាក់ស្តែង "ការទទួលខុសត្រូវនេះ" នាំឱ្យមានបញ្ហា យ៉ាងចម្រូងចម្រាស់ចោទឡើង។ ប្រសិនអ្នកផលិតបាល់ទាត់ នៃប្រទេស A ផលិតក្រោមអាជ្ញាប័ណ្ណផលិតផលសម្រាប់ក្រុមហ៊ុនពហុជាតិ នៃប្រទេស Bដោយប្រើប្រាស់កុមារនៅក្នុងរោងចក្ររបស់ខ្លួនបាល់ទាត់ទាំងនេះ បានត្រូវដឹកទៅលក់នៅក្នុងប្រទេស C ដូច្នេះអ្នកណាទទួលខុសត្រូវ ពិតប្រាកដចំពោះពលកម្មកុមារ? តើក្រុមហ៊ុននៅក្នុងប្រទេស B ប្រកាសថា ខ្លួន "មិនដឹង" អំពីរឿងដែលកុមារ ត្រូវគេប្រើឱ្យធ្វើការ? តើឃ្លាំងទំនិញនៅក្នុងប្រទេស C ដែលលក់ផលិតផល និងអះអាងថា មិនដឹងថា កុមារបានផលិតបាល់ទាត់ឬ? តើរដ្ឋាភិបាលនៃប្រទេស A ដែលមានច្បាប់ប្រឆាំងនឹងពលកម្មកុមារឬ? ឬក៏រដ្ឋាភិបាលប្រទេស B និង C ទទួលខុសត្រូវ ដោយសារមិនត្រួតពិនិត្យក្រុមហ៊ុនប្រទេសរបស់ខ្លួន ក្នុងបញ្ហាគោរពបទដ្ឋានគ្រឹះនៃពលកម្មនិងសិទ្ធិមនុស្សក្នុងសង្គមរបស់ខ្លួនឬទេ?

តើអ្នកប្រើប្រាស់ទទួលខុសត្រូវចំពោះវត្តមាននៃពលកម្មកុមារ និងចំពោះការខ្វះខាត ការត្រួតពិនិត្យឬទេ?

ក្នុងរយៈចុងក្រោយនេះយើងទាំងអស់គ្នា អាចទទួលខុសត្រូវ កាន់តែច្រើន ឬកាន់តែតិច។ សមាជិកសហគមន៍ ត្រូវតែមានតួនាទី និងនិយោជកមានតួនាទីសំខាន់ណាស់ក្នុងការឃ្លាំមើលកុំឱ្យក្រុមហ៊ុនរបស់ខ្លួនប្រើប្រាស់ ឬផ្គត់ផ្គង់កុមារក្នុងទំនាក់ទំនងពាណិជ្ជកម្ម។ បញ្ហាទាំងអស់នោះគឺជា បញ្ហាគ្រឹះនៃការស៊ើបអង្កេត និងការស្រាវជ្រាវរបស់ក្រុម។

ភាគច្រើននៃនិយោជក លុះត្រាតែក្រុមហ៊ុនគេមាន ទំហំតូច ទើបអាចធ្វើជាសមាជិកនៃសមាគមណាមួយបាន។

ជាញឹកញាប់សមាគមទាំងនេះអនុគ្រោះចំពោះអាកប្បកិរិយានៃសមាជិករបស់ខ្លួន។ ច្បាប់ទាំងនេះត្រូវបាន តាក់តែងឡើងដោយ យោងទៅតាមបទដ្ឋាននៃការងារដោយភ្ជាប់ទៅនិងពលកម្មកុមារផង។ សមាគមទាំងនេះ ជួនកាលជាកម្មសិទ្ធិរបស់សហព័ន្ធតំបន់ណាមួយ ឬសហជីពអន្តរជាតិនៃនិយោជក។ រឿងនេះមានន័យថា ឃ្លាំង ក្នុងស្រុកណាមួយអាចរួមចំណែក នៃបណ្តាញមួយយ៉ាងធំ







និងមានការទទួលខុសត្រូវជាក់លាក់ចំពោះបណ្តាញនេះ។ សូមលើកទឹកចិត្តយុវជនរបស់ក្រុមឱ្យរកឃើញនូវហេតុការណ៍ទាំងឡាយដែលកើតឡើងចំពោះនិយោជកដោយសារពលកម្មរបស់គេ។ យុវជនអាចរកឃើញអត្តសញ្ញាណអ្នកលក់បន្ត ដែលទុកដូចជាប្រធានបទសម្រាប់ការស្រាវជ្រាវរបស់គេ។

ក្រៅពីទំនាក់ទំនងផ្ទាល់ជាមួយនឹងទីចាត់ការនៃឃ្លាំងទំនិញ ដើម្បីពិភាក្សា រកវិធីភ្ជាប់ការអនុវត្តរបស់ពួកគេទៅនឹងពលកម្ម។

យុវជនត្រូវព្យាយាមស្រាវជ្រាវរកឱ្យឃើញការលក់បន្តទៅឱ្យសមាគមផ្សេងៗទៀត។ បន្ទាប់មកទៀតត្រូវប្រាស្រ័យទាក់ទងផ្ទាល់ នឹងសហគមន៍ចុងក្រោយនេះ ដើម្បីធ្វើការស្រាវជ្រាវស៊ីជម្រៅ។

រឿងនេះហាក់ដូចជាមានការពិបាកក្នុងការទាក់ទងពួកនិយោជកដោយផ្ទាល់ និងភ្ជាប់ពួកគេទៅនឹងបញ្ហា កុមារពលកម្មទៅនឹងបទដ្ឋានទាំងឡាយ នៃពលកម្ម ជាទូទៅ។

ពួកគេមិនអាចចាត់ទុកដូចជាអ្នកទទួលខុសត្រូវតែម្នាក់ឯងអំពីការបង្កើតពលកម្មកុមារទេ ប៉ុន្តែពួកគេត្រូវទទួលខុសមួយផ្នែកសំខាន់នៃការទទួលខុសត្រូវអំពីទម្រង់ និងលក្ខខណ្ឌការងារ បែបណាដែលអាចប្រើប្រាស់កុមារ។ និយោជកមួយចំនួន និងអង្គការរបស់គេធ្វើសហប្រតិបត្តិការជាមួយរដ្ឋាភិបាល សហជីព និងភ្នាក់ងារឯកទេសសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងពលកម្មកុមារឱ្យដល់ឫសគល់។

ដើម្បីជ័យជំនះនៃយុទ្ធាការពិភពលោកលុបបំបាត់ពលកម្មកុមារ អង្គត្រីភាគី ដ៏សំខាន់ត្រូវចូលរួមក្នុងសកម្មភាពទាំងឡាយ ដែលនាំមកនូវការប្រែប្រួលរីកចម្រើន។

## សមាព័ន្ធពាណិជ្ជកម្ម ឬអង្គការពលកម្ម



ជាធម្មតាសហជីពត្រូវតែធ្វើសកម្មភាពឱ្យខ្លាំងចំពោះអ្វីដែលទាក់ទង នឹងកិច្ចការពារបញ្ហាសង្គម,ការអភិវឌ្ឍន៍ និងសិទ្ធិមនុស្ស។ សហជីពត្រូវបាន បង្កើតឡើងមុនគេបង្អស់ ដើម្បីការពារសិទ្ធិបុគ្គលនៅកន្លែងធ្វើការ។ មនុស្ស ដែលធ្វើពលកម្ម ត្រូវតែដឹងថា (ចំពោះមុខ អំណាចសេដ្ឋកិច្ចរបស់និយោជក និងអំណាចនយោបាយរបស់រដ្ឋាភិបាល) ច្រកចេញតែមួយគត់គឺរួបរួមកម្លាំង របស់ខ្លួនដើម្បីកែលំអស្ថានភាព និងលក្ខខណ្ឌការងាររបស់ខ្លួន។ ក្នុងប្រទេស ឧស្សាហកម្មពលកម្មកុមារត្រូវបានផ្សព្វផ្សាយមុនដើមសតវត្សទី២០។ ជាសំខាន់បំផុតគឺដោយសារកម្លាំងសមូហភាពនៃចលនាសហជីព និងដោយ សារវិធានការផ្សេងៗនៃការអភិវឌ្ឍដែលប្រែប្រួល ការតែងច្បាប់ត្រូវបានកែ ទម្រង់ដែលការអប់រំត្រូវបានកែលំអ ដែលកុមារទាំងឡាយបានទទួលគុណ ប្រយោជន៍ អំពីកិច្ចការពារមួយដ៏ត្រឹមត្រូវ និងសមស្រប។

គោលបំណងជាមូលដ្ឋានរបស់សហជីព គឺការពារផលប្រយោជន៍ សមាជិករបស់ខ្លួន,ឃ្លាំមើលអ្វីដែលគេបានចំណេញពីលក្ខខណ្ឌការងារ សមរម្យទទួលបានប្រាក់បៀវត្សត្រឹមត្រូវ ហើយសិទ្ធិរបស់គេត្រូវបានគោរព ដោយនិយោជក និងអ្នកដទៃទៀត។ ជាមួយនឹងពេលវេលា និងការវិវត្តន៍ នៃស្ថានភាពសង្គម សេដ្ឋកិច្ច, តួនាទី និងការចូលរួមវិភាគទានរបស់សហជីព បានការវិវត្តន៍ទៅមុខ។

សហជីពបានក្លាយជាអង្គការនៃសេវាកម្មកាន់តែខ្លាំងឡើងៗ។ បច្ចុប្បន្ននេះ សហជីពពង្រីកផលប្រយោជន៍របស់គេដើម្បីស្គាល់បញ្ហាសង្គម ការអភិវឌ្ឍ និង មនុស្សធម៌ឱ្យបានច្រើន។ ដូច្នេះ,តំរិយាបថរបស់គេក្នុងឋានៈ ជាអង្គការសហគមន៍ ដែលមានសមត្ថកិច្ចត្រូវបានពង្រីក ហើយសហជីព មានលទ្ធភាពដើរតួយ៉ាងសំខាន់ក្នុងយុទ្ធការពិភពលោកដើម្បីការលុបបំបាត់ ពលកម្មកុមារ។



### កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

ផ្អែកទៅលើការបង្កើត និងការអភិវឌ្ឍនៃចលនាសហជីពពាណិជ្ជកម្មអន្តរជាតិ និងការកែទម្រង់ច្បាប់ការអំពាវនាវដល់គ្រូបង្រៀនផ្សេងទៀត ដែលអាចជួយក្រុមឱ្យរក្សាការស្រាវជ្រាវរបស់ខ្លួនដោយស្ថិតនៅក្នុងបរិបទអប់រំ គឺមានប្រយោជន៍។ ឧទាហរណ៍គ្រូបង្រៀនប្រវត្តិវិទ្យា បង្រៀនការសិក្សាសង្គម ការគ្រប់គ្រង និងសេដ្ឋកិច្ច អាចចូលរួមវិភាគទានផ្ដល់ព័ត៌មានចាំបាច់ ដែលយុវជនត្រូវការក្នុងក្របខ័ណ្ឌនៃការស្រាវជ្រាវរបស់គេ។ ម្យ៉ាងវិញទៀត សូមកុំភ្លេចថា សហជីពជាច្រើនបានតាក់តែងកម្មវិធីអប់រំសម្រាប់យុវជន ហើយគេត្រៀមមកចរចារជាមួយយុវជន ស្ដីអំពីប្រវត្តិនៃចលនាសហជីព។ សូមទាញយកផ្នែកដែលល្អនៃលទ្ធភាពរបស់គេដែលនឹងធ្វើឱ្យកិច្ចសន្យានៃសហគមន៍រីកចម្រើន។

ចលនាសហជីពរួមចំណែកក្នុងបណ្ដាញរបស់តំបន់ និងអន្តរជាតិដ៏ធំទូលំទូលាយ។ ផលប្រយោជន៍នឹងកម្លាំងសាមគ្គីភាពអន្តរជាតិ រវាងសហជីពនៃប្រទេសផ្សេងៗ អាចធ្វើឱ្យមានឋាមពល និងផលប៉ះពាល់ដ៏ធំសម្បើម។ នៅពេលស្រាវជ្រាវរបស់គេ យុវជននឹងមានលទ្ធភាពចោទជាសំណួរផ្សេងៗទៅកាន់សហជីពអំពីការចូលរួមក្នុងភូមិភាគ និងអន្តរជាតិ និងមានលទ្ធភាពប្រាស្រ័យទាក់ទងអង្គការទាំងនោះ ដើម្បីសុំព័ត៌មានអំពីសកម្មភាពផ្សេងៗរបស់គេ។

អង្គការសហជីពតំបន់ និងអន្តរជាតិមួយចំនួន យកចិត្តទុកដាក់ទៅលើបញ្ហាពលកម្មកុមារ និងគាំទ្រការងាររបស់ IPEC។ អង្គការទាំងនោះធ្វើសកម្មភាពផ្ទាល់របស់គេ និងអនុវត្តកម្មវិធីអប់រំពលកម្មកុមារក្នុងប្រទេសជាច្រើនក្នុងពិភពលោក។ ការរៀនស្គាល់កម្មវិធីផ្សេងៗ និងរៀនធ្វើវិភាគទៅលើការរួមវិភាគទានរបស់គេដល់យុទ្ធការលុបបំបាត់ពលកម្មកុមារអាចជួយពួកយុវជនឱ្យយល់តួនាទីសំខាន់របស់សហជីព និងប្រភេទនៃតួនាទីនេះ។

សហជីពទាំងឡាយស្ថិតជួរមុខនៃពិភពការងារ។ សមាជិករបស់គេត្រូវបានប្រើប្រាស់ក្នុងឬជិតកន្លែងដែលកុមារពលកម្មត្រូវបានគេប្រើប្រាស់។ ក្នុងករណីខ្លះគេមិនមែនមិនអាចរកឃើញសមាជិកម្នាក់របស់សហជីពណាមួយដែលធ្វើការជិតកុមារម្នាក់.ជាយថាហេតុ គឺជាកូនផ្ទាល់របស់គេតែម្ដង។

ស្ថានភាពនេះធ្វើឱ្យឃើញជាក់ស្ដែងនូវសារៈសំខាន់នៃការអប់រំ និងការចាប់អារម្មណ៍។ សហជីព និងសមាជិកសហជីពនោះអាចដើរតួ ជា "អ្នកត្រួតពិនិត្យ" ប្រកបដោយប្រសិទ្ធភាព។

ម្យ៉ាងទៀត,ដោយសារដំណើរនៃការ"សន្ទនាសង្គម"សហជីពអាចធ្វើការជាមួយរដ្ឋាភិបាលទាំងឡាយ និងនិយោជកដើម្បីកំណត់យកយុទ្ធសាស្ត្រ ការពារទុកជាមុនចំពោះពលកម្មកុមារ ។ កុមារទាំងឡាយត្រូវបានគេប្រើឱ្យធ្វើការជំនួសមនុស្សពេញវ័យហើយការធ្វើការវិភាគទៅលើមូលហេតុនៃបាតុភូតនេះ ។ ដោយប្រមូលផ្តុំការប្រឹងប្រែងរបស់គេ សហជីពសុទ្ធតែខ្លាំង ហើយត្រូវបានរៀបចំពោះពលកម្មកុមារនឹងមិនមានឡើយ ។

គឺជាការជាក់ស្តែងឡើង ដែលទិសដៅមួយនៃទិសដៅលុបបំបាត់ពលកម្មកុមារទាំងឡាយ ត្រូវអនុគ្រោះ ហើយគាំទ្រសហជីពខ្លាំងៗ ។

ដូច្នេះ,ហេតុអ្វីបានជាពលកម្មកុមារកើតមាននៅក្នុងប្រទេស ដែលមានសហជីព និងដែលមានច្បាប់ហាមឃាត់ ។ ក្នុងប្រទេសទាំងនេះមានបញ្ហាអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច,ភាពក្រីក្រ វប្បធម៌ និងប្រពៃណីខុសគ្នា ខ្វះខាតការអប់រំ ខ្វះហេដ្ឋារចនាសម្ព័ន្ធអប់រំ និងបំណុលពីខាងក្រៅ ហើយនិងបញ្ហាផ្សេងទៀត ។ រឿងទាំងនេះ មិនមែនជាបញ្ហាពិបាកឡើយ ពីព្រោះគេមានសហជីព ដែលរារាំងពលកម្មកុមារមិនឱ្យមានតទៅទៀត ។ សហជីពរួមចំណែកក្នុងការដោះស្រាយនេះជាផ្នែកមួយដែលសំខាន់ ប៉ុន្តែមានដៃគូផ្សេងៗទៀតជាច្រើនដែលត្រូវធ្វើការជាមួយគ្នា ដើម្បីឱ្យមានការប្រែប្រួល ។

សូមពិភាក្សាជាមួយក្រុមទាំងមូលអំពីរបៀបធ្វើការបង្ហាញពន្យល់ ។ ពន្យល់ដល់សមាជិកក្រុមថា មានវិធីដែលមានប្រសិទ្ធភាព និងមិនសូវមានប្រសិទ្ធភាពក្នុងការផ្តល់ព័ត៌មាន ។ វិធីដែលមិនសូវមានប្រសិទ្ធភាពគឺការនិយាយយ៉ាងញាប់ ធ្វើឱ្យស្ថិតិកាន់តែស្មុគ្រស្មាញឡើងដែលធ្វើឱ្យសាធារណៈជនទាល់គំនិត និងធ្វើឱ្យមានការពិបាក សម្រាប់ពួកគាត់ ក្នុងការតាមដានថា តើមានអ្វីកើតឡើង ។

សូមបញ្ជាក់គំនិតដែលថា សមាជិកក្រុមម្នាក់ៗត្រូវបានឱ្យពន្យល់បង្ហាញក្នុងវិធានការមួយ ។ សូមបញ្ជាក់ដល់ក្រុមថា លោកអ្នកមិនអាចរង់ចាំភាពយន្តឯកសារណា និងបញ្ជាក់ថា ការសំដែងទាំងឡាយមិនត្រូវឱ្យវែងពេកទេ ។ វិធីសំដែងដែលមានប្រសិទ្ធភាពជាងគេគឺ វិធីសំដែងដែលមានការអបអរសាទររបស់សាធារណជនដែលមានផលប្រយោជន៍ដល់គេ ដែលធ្វើឱ្យគេសើចថែមទាំងឱ្យគេចូលរួមហើយដែលនឹងជួយគេកុំឱ្យភ្លេចព័ត៌មានទាំងឡាយ ព្រោះគេនឹងចងចាំដល់

ការសម្តែង ។ វិធីទាំងអស់នេះអាចមាន ៖ ការប្រើប្រាស់ឧបករណ៍ បញ្ចាំងស្លាយ ជំរុញឱ្យមានការទាក់ទាញផ្នែកចក្ខុវិញ្ញាណ

*ការបង្ហាញលទ្ធផល*



- ការប្រើប្រាស់ល្បែងដើរតួ សូមលើកទឹកចិត្តពួកយុវជនឱ្យខំធ្វើការសម្តែងក្រោមរូបភាពល្បែងដើរតួ ឧទាហរណ៍ អ្នកសម្ភាសន៍ និងត្រូវគេធ្វើសម្ភាសន៍ ព្រឹត្តិប័ត្រព័ត៌មាន សម័យប្រជុំ ។ល ។ លទ្ធភាពច្រើនណាស់ហើយល្បែងដើរតួនាំឱ្យសាធារណជនសប្បាយពិតប្រាកដ ។
- ការប្រើប្រាស់វិធីសាស្ត្រអន្តរកម្ម ឧទាហរណ៍ទៅតាមទស្សនៈនៃកម្មវិធីបញ្ចាំងតាមទូរទស្សន៍ដោយមានការចូលរួមពីសំណាក់សាធារណៈជនដែលចូលរួមសំដែងមតិ ឬក្នុងការលើកឡើងនូវសំណួរផ្សេងៗ និងដោយមានអ្នកឯកទេស ឬអ្នកជំនាញត្រៀមចាំឆ្លើយចំពោះសំណួរទាំងនោះ ។

សូមធ្វើសេចក្តីផ្តើមមុននឹងធ្វើការសម្តែងបកស្រាយ និងសូមពន្យល់អំពីការប្រើប្រាស់សំនួនវោហារ និងភាសារបស់ខ្លួន ដើម្បីបញ្ជូនព័ត៌មានទៅឱ្យសាធារណជន។ ប្រសិនបើលោកអ្នកអាចទាក់ទងធនធានមនុស្សពីខាងក្រៅដែលគេអាចជួយលោកអ្នកក្នុងពេលប្រជុំនេះ សូមលោកអ្នកប្រើប្រាស់គេទាំងនោះចុះ។ ឧទាហរណ៍ប្រសិនបើលោកអ្នកស្ថិតក្នុងក្របខ័ណ្ឌសិក្សា លោកអ្នកប្រហែលជាមានក្រុមពិភាក្សាមួយ ហើយលោកអ្នកអាចអញ្ជើញគ្រូបង្រៀនដែលទទួលខុសត្រូវនៃក្រុមនោះ។ ម្យ៉ាងទៀតឪពុកម្តាយភាគច្រើនអាចមានបទពិសោធន៍ វិជ្ជាជីវៈអំពីការរៀបចំ និងធ្វើឱ្យការសម្តែងបានសម្រេច។

ដើម្បីជំរុញការប្រជុំ សូមបង្កើតការប្រឡងប្រជែងតូចមួយរវាងក្រុមទាំងឡាយ ដើម្បីបង្កើតឱ្យមានចំណាប់អារម្មណ៍ថែមទៀត និងបញ្ចូលឈុតកំប្លែងស្ងួតផង ឧទាហរណ៍ :

- រង្វាន់សម្រាប់ការសម្តែងដែលនាំឱ្យមានការចាប់អារម្មណ៍ខ្លាំងជាងគេ។
- រង្វាន់សម្រាប់ការសំដែងដែលបង្កើតថ្មីបំផុត។

ក្រុមនីមួយៗត្រូវធ្វើរបាយការណ៍មួយអំពីលទ្ធផលសម្រាប់អាន ក្នុងបន្ទប់ដែលមានការជួបជុំគ្នាជាទៀងទាត់។ របាយការណ៍ទាំងនេះនឹងរួមវិភាគទានដល់ដំណើរការចងក្រងព័ត៌មាន និងដល់ស្មារតីគម្រោង។

របាយការណ៍ទាំងនោះមានប្រយោជន៍ដល់ការសម្ភាសន៍ និងសំរាប់ការអនុវត្តលើកទីពីរ។



## សកម្មភាព២ ការសម្ភាសន៍

*ការបង្រៀនពីរពេល*

ក្រុមនីមួយៗជ្រើសរើសបេក្ខជនម្នាក់សម្រាប់សម្ភាសន៏អំពីសហគមន៏ត្រីភាគីផ្សេងៗគ្នា រដ្ឋាភិបាល អង្គការពលកម្ម និងអង្គការនិយោជក។ សូមចាំថានៅក្នុងម៉ូឌុលដែលមានចំណងជើងថា "សន្ទនា និងអង្កេត" បានណែនាំឱ្យភ្ជាប់ស្ថាប័នផ្សេងៗទាំងនេះទៅនឹងគម្រោងដោយអញ្ជើញអ្នកនយោបាយ អ្នកមានភារកិច្ច ឬសហជីពឱ្យមកនិយាយជម្រាបដល់ក្រុម អំពីប្រធានបទនៃគម្រោង ឬពិនិត្យការងាររបស់យុវជនក្រោមរូបភាព នៃការពិភាក្សា ឬការសំដែងជាល្ខោន។ ការសម្ភាសន៏អាចត្រូវបានក្នុងឱកាសទស្សនកិច្ចរបស់តំណាងទាំងនេះ។

### កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់



យើងសូមឱ្យលោកអ្នកមើល ម៉ូឌុល "សន្ទនា និងអង្កេត" ដើម្បីរៀបចំការងារនេះ។ គេនឹងរំលឹកដល់លោកអ្នក និងក្រុមរបស់លោកអ្នកអំពីរបៀបធ្វើការសម្ភាសន៏ ការទូន្មាន និងការផ្តល់គំនិតដែលទាក់ទងនឹង "ការបំផុសគំនិត" និងការជ្រើសរើសបេក្ខជន និងរបៀបទាក់ទងជាមួយបេក្ខជន,របៀបប្រើប្រាស់វីដេអូ របៀបធ្វើការសម្ភាសន៏ទាំងអស់នេះ ជាទិដ្ឋភាពដែលសំខាន់ជាងគេបង្អស់នៃការអនុវត្តនេះ។

ក្រុមប្រហែលជាបានធ្វើសម្ភាសន៏ផ្ទាល់នឹងតំណាងសហគមន៏ដែលពាក់ព័ន្ធ (រួចហើយ)។ ប្រសិនបើមានករណីដូចនេះសូមកុំធ្វើកិច្ចការនេះ ហើយធ្វើដំណើរត្រង់ឆ្ពោះទៅសកម្មភាពចុងក្រោយតែម្តង។ លោកអ្នកអាចធ្វើការសម្ភាសន៏ជាថ្មីទៀត ជាមួយអ្នកតំណាងដែលលោកអ្នកមិនបានគិតទុកពីមុនមក។

ព័ត៌មានគ្រឹះដែលត្រូវបានបង្ហាញក្នុងសកម្មភាពទីមួយ និងក្នុងម៉ូឌុល "សន្ទនា និងអង្កេត"និងជួយក្រុមឱ្យស្នើឡើងនូវបញ្ហាមួយចំនួន ទៅមនុស្សដែលត្រូវទទួលការសម្ភាសន៏។

# សកម្មភាព៣ ការពិភាក្សាត្រីភាគីស្ដីពីពលកម្មកុមារ

*បង្រៀនម្ដង ម្ដង២ពេល*

*បន្ថែម១ពេលសម្រាប់ការអនុវត្តលំហាត់ជាក់ស្ដែង*



## កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

គេគួរតែអនុវត្តម៉ូឌុល "ពិភាក្សា" មុននឹងផ្ដើមសិក្សាម៉ូឌុល "ពិភពការងារ"។ ការ "ពិភាក្សា"ក្នុងលំហាត់នេះនឹងត្រូវយកតាមទម្រង់នៃការពិភាក្សារបស់សភា បានសេចក្ដីថា កាន់តែត្រឹមត្រូវថែមទៀត។ គេមិនបានទូន្មានឱ្យប្រើប្រាស់ទម្រង់"ពិភាក្សាចល័ត"ទេ ចំពោះកិច្ចការនេះ។ សូមលោកអ្នកស្នើទៅក្រុមរបស់លោកអ្នកឱ្យរ៉ាប់រង ប្រើប្រាស់តួនាទីដៃគូត្រីភាគី។

អំណើះតទៅក្រុមទាំងអស់មានមនសិការខ្លាំងជាងមុន អំពីតួនាទីផ្សេងៗ និងមុខងារនៃដៃគូត្រីភាគី និងជាឱកាសល្អមួយសម្រាប់សាកល្បង និងប្រើប្រាស់ចំណេះដឹងទាំងនេះ។ សម្រាប់សកម្មភាពនេះ សូមបង្កើតអនុក្រុមចំនួន៣ ក្រុមនីមួយៗតំណាងឱ្យដៃគូត្រីភាគីមួយ : រដ្ឋាភិបាល និយោជក និងពលករ។ គោលបំណងគឺជួយក្រុមឱ្យប្រមូលផ្ដុំការយកចិត្តទុកដាក់របស់ខ្លួនទៅលើទស្សនៈវិស័យ របស់ដៃគូនីមួយៗ អំពីពលកម្មកុមារ។ ពួកយុវជននឹងត្រូវជជែកគ្នាទៅវិញទៅមកអំពីបញ្ហាពាក់ព័ន្ធនឹងពលកម្មកុមារ។

នេះគឺជាការអនុវត្តន៍ជាមូលដ្ឋានមួយដែលពាក់ព័ន្ធទៅនឹងការបញ្ចូល ដៃគូត្រីភាគីក្នុងគម្រោងរបស់អ្នក វានឹងនាំឱ្យយុវជនដើម្បីពិនិត្យពិច័យពលកម្មកុមារ និងសិទ្ធិកុមារក្រោមទស្សនៈវិស័យខុសៗគ្នា។

នៅពេលវិភាគបញ្ហាទាំងអស់នេះជារួម ស្ដីអំពីទស្សនៈរបស់ក្រុមផ្សេងៗនោះព្រំដែននៃការយល់ដឹងគេនឹងត្រូវពង្រីក យុវជននឹងមានការយល់ដឹងយ៉ាងប្រពៃអំពីការកើតមានបញ្ហាដូចនេះ និងអំពីសារៈសំខាន់ ដែលគ្របដណ្ដប់លើតួនាទី របស់អ្នកសម្ដែងគ្រប់ៗគ្នានៅក្នុងសង្គមក្នុងគោលបំណងរកឱ្យឃើញ និងអនុវត្តរាល់ដំណោះស្រាយ។ ខ្លឹមសារតែមួយគត់ដែលត្រូវទទួលយកធ្វើជាប្រធានបទនៃការពិភាក្សា មានដូចតទៅ: "ប្រធានបទ"មួយ និង"ដំណោះស្រាយ" មួយឬ "ញត្តិ"ដែលនឹងកំណត់ប្រភេទ និងអ្វីដែលបានសម្រេច នៃការពិភាក្សាដំបូងនៃម៉ូឌុលពិភាក្សាក្រុមនឹងទទួលរ៉ាប់រងស្ថានភាពនៃការ

យល់ព្រមឬជំទាស់ញត្តិ ប៉ុន្តែដោយចាត់ទុកនយោបាយ និងបរិបទរបស់ដៃគូត្រីភាគី ជាប្រធានបទ ដើម្បីបង្ហាញភស្តុតាងគាំទ្រស្ថានភាពរបស់គេ ដើម្បីសម្រេចកិច្ចព្រមព្រៀងមួយសម្រាប់ទាំងអស់គ្នា។

សម្រាប់លំហាត់ពិភាក្សា,យើងត្រូវតែមានប្រធានបទ និងដំណោះស្រាយរបស់វា ឬត្រូវមានការសម្តែងមតិ ដែលអាចកំណត់ច្បាស់នូវកម្រិតយល់ដឹងស្តែងចេញពីការពិភាក្សា។ នៅក្នុងលំហាត់ដំបូងដែលមាននៅក្នុងសៀវភៅ "ការពិភាក្សា"នោះ ក្រុមទាំងឡាយនឹងស្ថិតក្នុងជំហរគាំទ្រ និងប្រឆាំងការសម្តែងមតិ។ នៅក្នុងលំហាត់នេះ ជាពិសេសមិនមែនការគាំទ្រ និងការជំទាស់យ៉ាងសាមញ្ញប៉ុណ្ណោះ ក៏ប៉ុន្តែលំហាត់នេះនាំឱ្យយល់ដឹង អំពីនយោបាយ និងបរិបទនៃដៃគូត្រីភាគីនីមួយៗចំពោះប្រធានបទ ហើយនាំឱ្យដៃគូបង្ហាញអំណះអំណាងលំអិតនៅក្នុងគោលជំហររបស់គេក្នុងគោលបំណងឈានឱ្យដល់ការព្រមព្រៀងគ្នាមួយ ដែលអាចទទួលបាន និងឈានឱ្យដល់ការសម្រេចចិត្តរួមគ្នា។

ប្រធានបទតែមួយគត់ សម្រាប់ការពិភាក្សាក្នុងកិច្ចការនេះគឺ **"ការការពារកុមារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច"**

អនុក្រុមរងនីមួយៗនឹងជួបជុំគ្នា នៅនឹងកន្លែងរបស់ខ្លួន ដើម្បីពិភាក្សាគ្នាអំពីប្រធានបទ ដោយរាប់បញ្ចូលទាំងការពិចារណាដូចខាងក្រោម។

សូមលោកអ្នកកត់សម្គាល់ថា អ្នកទាំងនេះមិនធ្វើតាមបទបញ្ជាណាមួយទេ ដោយហេតុថា បញ្ជីនេះគឺវែងបង្គួរ និងលំអិតគ្រប់ផ្នែកបង្គួរ អាចឱ្យលោកអ្នកធ្វើការចម្លងជាមុនហើយចែកឱ្យអនុក្រុមនីមួយៗ។ សូមចំណាយពេលបន្តិចសម្រាប់និយាយអំពីប្រធានបទ នៃការពិភាក្សា និងអានបញ្ជីកម្រងសំណួរដោយរ៉ាប់រងថា សមាជិកនៃក្រុមនីមួយៗ យល់នូវអ្វីដែលគេនឹងធ្វើក្នុងលំហាត់បញ្ចប់។

វត្ថុបំណងគឺឱ្យអនុក្រុមនីមួយៗពិភាក្សានូវបញ្ហាស្តីពីទស្សនៈរបស់ដៃគូត្រីភាគីដែលអនុក្រុមតំណាងឱ្យ។ ដៃគូនីមួយៗ "រដ្ឋាភិបាល និយោជក និងពលករ" នឹងសម្រេចបានបញ្ហាទាំងនេះតាមបែបផ្សេងៗទៅតាមតួនាទី និងការទទួលខុសត្រូវផ្ទាល់ខ្លួន របស់គេ។

**និយមន័យនៃពាក្យ "កុមារ"**

- តើគួរឱ្យនិយមន័យដូចម្តេចចំពោះ "កុមារ" ដោយគិតទៅតាមអាយុរបស់គេតើគេត្រូវប្រកាន់យកទិដ្ឋភាពផ្សេងទៀត ដើម្បីកំណត់អត្ថន័យ របស់កុមារ ឬទេ?

- តាមយោបល់ដៃគូត្រីភាគីនិមួយៗតើការងាររបស់កុមារមានន័យដូចម្តេច?

**ការអប់រំ**

- ការសិក្សាត្រូវតែជាកាតព្វកិច្ចឬ?
- ប្រសិនបើការពិភាក្សាជាកាតព្វកិច្ចកុមារអាចចាកចេញពីសាលារៀននៅអាយុប៉ុន្មាន?
- តើគេត្រូវបង្កើតលក្ខណៈការងារពិសេសដូចម្តេច សម្រាប់កុមារដែលនៅសិក្សាឯសាលារៀននៅឡើយ?

## កម្រិតទាបបំផុតនៃអាយុការងារ

- តើកុមារអាចនឹងចូលបម្រើការងារនៅអាយុប៉ុន្មាន? តើកុមារត្រូវឱ្យអប្បបរមាប៉ុន្មាន ដើម្បីឱ្យចូលធ្វើពលកម្មក្នុងប្រទេស ។
- តើអាយុអប្បបរមា ត្រូវតែដូចគ្នាទាំងអស់សម្រាប់គ្រប់ទម្រង់នៃការងារឬ? តើត្រូវកំណត់អាយុផ្សេងៗពីគ្នា ទៅតាមប្រភេទនៃការងារឬ? ឧទាហរណ៍ តើត្រូវមានអាយុច្រើនបន្តិចសម្រាប់ទម្រង់ប្រកបដោយគ្រោះថ្នាក់ ដូចជាការងារក្នុងអណ្តូងរ៉ែក្នុងតំបន់យោធា ការងារពេលយប់ការងារជាមួយនឹងគ្រឿងម៉ាស៊ីន... ។ល ។ ឬ?



## និយមន័យនៃពាក្យ "ការងារ"

- តើពាក្យ "ការងារ" ត្រូវមាននិយមន័យដូចម្តេចនៅពេលដែលកុមារត្រូវបានអនុញ្ញាតឱ្យធ្វើការងារ? ឧទាហរណ៍, បើកុមារនៅរៀននៅឡើយ តើគេត្រូវបានអនុញ្ញាតឱ្យធ្វើការឬទេ? ដូចជា ការងារពាក់កណ្តាលពេលជាដើម? តើគេត្រូវធ្វើចំណាត់ថ្នាក់ នៃការងារដូចម្តេច ឧទាហរណ៍ស្រាល មធ្យម និង លំបាក?
- ដោយប្រៀបនឹងកុមារដែលបំពេញការងារនៅតាមផ្ទះ នៅតាមគ្រួសារ កសិដ្ឋានរបស់គ្រួសារបន្ត? តើគេត្រូវអនុញ្ញាត ឱ្យកុមារធ្វើការប្រភេទនេះផង ទៅរៀនផងបានដែរឬទេ?តើគេត្រូវកំណត់ការងារឬទេ? ដើម្បីការពារកុមារក្នុងកាលៈទេសៈនេះ?
- ប្រសិនបើគេអនុញ្ញាតឱ្យកុមារធ្វើការងារស្រាលៗ តើគេអាចឱ្យនិយមន័យការងារនេះដូចម្តេច? តើគេត្រូវធ្វើការកំណត់ការងារនោះដូចម្តេច? ឧទាហរណ៍, គេបើកឱកាសឱ្យប្រភេទការងារនេះ ជ្រៀតចូលទៅក្នុងការអប់រំរបស់កុមារ ឬបំផ្លាញសុខភាពផ្លូវកាយ និងបញ្ញារបស់គេឬទេ?

## លក្ខខណ្ឌនៃការងារ

- តើយុវជនត្រូវធ្វើការប៉ុន្មានម៉ោង  តាមប្រភេទការងារនីមួយៗឧទាហរណ៍ អ្នកដែលធ្វើការផងរៀនផង។
- អ្នកដែលត្រូវបានអនុញ្ញាតឱ្យចាកចេញពីសាលារៀន  ហើយធ្វើការពេញម៉ោង? អ្នកដែលបំពេញការងារប្រកបដោយគ្រោះថ្នាក់ ឬបំផ្លាញសុខភាពរបស់ពួកគេ?
- តើគេត្រូវបង្កើតតារាងអត្រាប្រាក់បៀវត្សអប្បបរមាសម្រាប់កុមារ  និងយុវជនដែលធ្វើការងារឬទេ?  តើគេត្រូវធ្វើតារាងអត្រាបៀវត្សសម្រាប់កុមារដែលធ្វើការងារ និងរៀនផងឬទេ? តើគេត្រូវកម្រិតតារាងផ្សេងៗគ្នាសម្រាប់យុវជន ដែលមានវ័យខុសគ្នាទេ? តើតារាងអត្រាទាំងនោះ ត្រូវកំណត់ដូចម្តេច?
- តើគេនឹងត្រូវយល់ព្រមឱ្យមានការប្រុងប្រយ័ត្នពិសេសសម្រាប់បញ្ហាទាក់ទងនឹងសុខភាព និងសន្តិសុខនៅទីកន្លែងធ្វើការដែលកុមារ និងយុវជនបានធ្វើការ មិនថាពេលវេលាមិនពេញម៉ោង ឬពេញម៉ោង ឬទេ?

## *ការងារប្រកបដោយគ្រោះថ្នាក់ /ទម្រង់ធ្ងន់ធ្ងរនៃអាជីវកម្ម*



- តើគេត្រូវឱ្យនិយមន័យដូចម្តេចចំពោះ"ការងារប្រកបដោយគ្រោះថ្នាក់?
- តើត្រូវមានឥរិយាបថដូចម្តេចចំពោះដៃគូត្រីភាគីក្នុងករណីដែលកុមារទទួលរងអាជីវកម្មផ្លូវភេទ?

  ឬក្នុងស្ថានភាពដែលត្រូវបានគេគំរាមកំហែងឱ្យប្រព្រឹត្តនូវសកម្មភាពខុសច្បាប់ទាំងឡាយ  ដូចជាការធ្វើចរាចរថ្នាំញៀន  ឬបទឧក្រិដ្ឋផ្សេងៗទៀត? តើការងារនេះនឹងក្លាយទៅជាអ្វី ដែលស្ថិតនៅក្នុងការងារគ្រោះថ្នាក់ទាំងនេះចំពោះសុខមាលភាពរបស់គេ ចំពោះគ្រួសារគេ ។ល។ តើមានអ្វីកើតឡើងចំពោះអ្នកទាំងឡាយណា  ដែលបង្ខំកុមារឱ្យស្ថិតនៅក្នុងផ្លូវភេទ ឬបទឧក្រិដ្ឋឬទេ?
- តើដៃគូត្រីភាគីនឹងមានគោលជំហរដូចម្តេចនៅក្នុងការជួញដូរកុមារ?  តើសកម្មភាពនេះ គេអាចត្រួតពិនិត្យ  ឬហាមឃាត់ដូចម្តេច? តើមានអ្វីកើតឡើងក្នុងស្ថានភាពដែលគ្រួសារនៃកុមារទាំងនេះត្រូវគេរាប់បញ្ចូលទៅ

## ការត្រួតពិនិត្យ

- តើដៃគូត្រីភាគីទាំងឡាយធ្វើការត្រួតពិនិត្យដូចម្តេចចំពោះការធ្វើអាជីវកម្មកុមារដោយរំលោភសិទ្ធិរបស់កុមារ តើដៃគូត្រីភាគីត្រូវធ្វើការជាមួយគ្នាឬទេ? តើរឿងនោះគឺជាការទទួលខុសត្រូវរបស់ដៃគូពិសេសណាមួយឬ? តើគេអាចធ្វើដូចម្តេច? តើប្រព័ន្ធ និងនិតិវិធីបែបណាដែលគេត្រូវរៀបចំ?
- តើបុគ្គលិកក្រុមហ៊ុន ឬអង្គការទាំងឡាយដែលរំលោភច្បាប់ក្នុងការប្រើកុមារ ឱ្យធ្វើការងារនឹងត្រូវទទួលទោសបែបណា? តើគេត្រូវមានប្រព័ន្ធសម្រាប់ជាប់ពិរុទ្ធបែបណា?
- តើដៃគូត្រីភាគីទាំងឡាយ អាចប្រុងប្រយ័ត្នដូចម្តេចចំពោះពលកម្មកុមារ ចំពោះអ្វីដែលសមាជិកដទៃទៀតនៃសមាគមយល់ថា នេះគឺជាអំពើអាក្រក់មួយ ដែលចាំបាច់មាននូវការចូលរួមចំណែកទាំងអស់គ្នា ដើម្បីលុបបំបាត់ចោល?
- តើពលកម្មកុមារត្រូវតែលុបបំបាត់ទាំងស្រុងពីសង្គម ឬទេ?
- តើមានករណី ឬតំបន់ទាំងឡាយដែលនឹងអាចអនុគ្រោះដោយប្រការណាមួយឬទេ? តើអ្នកណាជាអ្នកធ្វើការសម្រេចចិត្ត និងអ្នកណាជាអ្នកត្រួតពិនិត្យស្ថានភាពទាំងនេះ?

ឃុតនីមួយៗនៃការពិចារណានឹងនាំមកនូវការពិចារណាផ្សេងទៀតតាមលំដាប់នៃការពិភាក្សា នេះគឺជាការល្អណាស់។ គោលបំណងមិនមែនគ្រាន់តែផ្តល់ នូវបញ្ជីសំណួរប៉ុណ្ណោះទេ។ ដូច្នេះការថ្លៃប្រឌិតការស្រមើស្រមៃរបស់យុវជន ដែលជាអ្នកចូលរួមមិនអាចជួបឧបសគ្គឡើយ ពួកអ្នកចង់ឱ្យយុវជនសម្តែងឡើងនូវគំនិតផ្ទាល់ខ្លួនរបស់ពួកគេ។

ម្យ៉ាងទៀតលោកអ្នកនឹងរកឃើញនៅក្នុងឧបសម្ព័ន្ធរបស់ម៉ូឌុលនេះនូវបញ្ជីប្រធានបទ និងបញ្ហាចែកជា ផ្នែករងដូចជា "ក្រុមរដ្ឋាភិបាល" "ក្រុមនិយោជក" និង "ក្រុមពលករ" ដែលនឹងជួយយុវជនឱ្យគេយល់បានប្រសើរនូវកង្វល់ និងផលប្រយោជន៍ នៃដៃគូត្រីភាគីនីមួយៗហើយនិងលើកឡើង ឱ្យពិនិត្យនូវអនុសាសន៍របស់គេនៅលើមូលដ្ឋាននេះ។ ជាការប្រសើរ គឺត្រូវរៀបចំឱ្យការពិភាក្សាដាច់ដោយឡែកពីគ្នា ចំពោះឧបសម្ព័ន្ធនេះ ជាមួយតំណាងរបស់ក្រុមនីមួយៗ ដោយការផ្តោតទៅលើទិដ្ឋភាព ដែលពាក់ព័ន្ធដល់ពួកគេ។ សូមឱ្យគេចូលរួមការពិភាក្សាដើម្បីបញ្ជាក់ថា ពួកគេបានយល់ស្ថានភាពទាំងឡាយដែលគេនឹងត្រូវអនុម័តិតាមរយៈបញ្ហាផ្សេងៗ។ ប្រសិនបើលោកអ្នកវាយតម្លៃថា រឿងនោះមានប្រយោជន៍ សូមអ្នកថតចម្លងឧបសគ្គនោះ ហើយចែកឱ្យក្រុមដែលបានពាក់ព័ន្ធ។



សូមទុកពេលគ្រប់គ្រាន់ឱ្យក្រុមសម្រាប់ការពិភាក្សា និងការរៀបចំ។

គោលបំណងនៃលំហាត់ផ្នែកនេះ គឺក្រុមនីមួយៗដាក់ឱ្យពិនិត្យនូវបញ្ជីអនុសាសន៍ដែលការពារកុមារទប់ទល់នឹងអាជីវកម្មសេដ្ឋកិច្ច និងសេចក្តីប្រកាស ស្តីពីគោលជំហររបស់គេ។ អនុសាសន៍ និងសេចក្តីប្រកាសត្រូវឆ្លុះបញ្ចាំងនូវទស្សនះរបស់ដៃគូ។

ក្រុមនីមួយៗត្រូវការជាញឹកញាប់នូវវិភាគទាន និងជំនួយរបស់លោកអ្នក ដូច្នេះក្នុងចំណោមពួកគេ ទាំងអស់គ្នា សូមឱ្យដំបូន្មានគេ និងលើកទឹកចិត្តដល់ពួកគេ សូមលោកដឹងឱ្យច្បាស់ថាតំណាងក្រុមនីមួយៗបានចូលរួម ក្នុងការពិភាក្សាតាមរបៀបរបស់គេ។ ក្រុមនីមួយៗត្រូវចាត់តាំងអ្នករាយការណ៏ម្នាក់ ឬច្រើននាក់ដើម្បីកត់ត្រាអនុសាសន៍ទាំងឡាយ។



សមាជិកម្នាក់ៗ ត្រូវចាត់តាំងអ្នកនាំពាក្យម្នាក់ ឬច្រើននាក់ ជាតំណាង ក្នុងការពិភាក្សា ត្រីភាគីជាទីបញ្ចប់។ ពិតមែន ហើយ អ្នកនាំពាក្យមានលទ្ធភាពស្នើយោបល់ក្រុមរបស់ខ្លួន ជានិច្ច ថែមទាំងស្នើសុំឱ្យសមាជិកផ្សេងទៀត ជជែកគ្នាអំពី បញ្ហាជាក់លាក់មួយចំនួនក្នុងនាមនៃក្រុម។

***ជំនួយពីខាងក្រៅ***

នៅក្នុងបញ្ហាខាងលើ និងក្នុងឧបសម្ព័ន្ធនៃម៉ូឌុលនេះ លោកអ្នកអាចពិនិត្យ ឃើញថាវាមានប្រយោជន៍ ការផ្ដល់ជំនួយបន្ថែមសម្រាប់ការអនុវត្ត ឧទាហរណ៍ ប្រសិនបើលោកអ្នកស្ថិតនៅក្នុងបរិបទអប់រំក្នុងប្រព័ន្ធ សូម អ្នកជំរុញគ្រូបង្រៀនឱ្យមានចំណេះដឹងផ្នែកសេដ្ឋកិច្ច សិក្សាសង្គម ភូមិវិទ្យា និងការគ្រប់គ្រង ដើម្បីជួយក្រុមទាំងអស់ក្នុងការរៀបចំខ្លួន សម្រាប់ការពិភាក្សា។

គ្រូបង្រៀន ទាំងនេះ ត្រូវសិក្សាស៊ីជំរៅបញ្ហាទាំងនេះ និងជួយក្រុមក្នុងការ លំអិតបញ្ហាទាំងនោះឱ្យកាន់តែពិស្ដារឡើង។

ម្យ៉ាងវិញទៀតការអនុវត្តនេះផ្ដល់ឱកាសដ៏ល្អមួយដល់លោក-អ្នកឱ្យអញ្ជើញតំណាងនៃរដ្ឋាភិបាល អង្គការនិយោជក និងពលករ ទាំងអស់ឱ្យមកជួយក្រុមនីមួយៗ ដើម្បីរៀបចំអំណះអំណាងរបស់ខ្លួន សម្រាប់ការពិភាក្សា។ សកម្មភាពនេះផ្ដល់តម្លៃយ៉ាងសម្បើមសម្រាប់ យុវជនក្នុងក្រុមរបស់លោកអ្នក ក៏ដូចជាសម្រាប់សហគមន៍ផ្សេងៗ ដែល បានធ្វើការសន្យានៅក្នុងគម្រោង។

សម្រាប់សកម្មភាពនៃការពិភាក្សាសូមលើកឡើងវិញនូវម៉ូឌុល "ពិភាក្សា" និងជាពិសេសលើកឡើងនូវផ្នែក "ការចាប់ផ្ដើម" និងការ "រៀបចំក្រុម"។ ថ្វីបើហេតុការណ៍ ដែលអនុវត្តក្នុងម៉ូឌុលនេះ មានទម្រង់ នៃការពិភាក្សាកាន់តែជាក់លាក់ថែមទៀតនោះ ក្រុមមិនសំដែងចេញនូវ គំនិតគាំទ្រ ឬជំទាស់នឹងមតិទាំងឡាយនៅក្នុងសកម្មភាពដ៏ត្រឹមត្រូវ។ ការធ្វើសវនការមិនមែនជាគំនិតល្អ ក្នុងក្របខ័ណ្ឌនៃការអនុវត្តន៍នេះ ពីព្រោះក្រុមផ្សេងៗការពារស្ថានភាពផ្ទាល់របស់គេ។

*ជំនួយពីខាងក្រៅ*

ប៉ុន្តែការប្រើប្រាស់ជំនួយពីខាងក្រៅ និងការអញ្ជើញតំណាងទាំងឡាយរបស់ដៃគូត្រីភាគី គឺជាគំនិតមួយល្អបំផុត។

ទ្រង់ទ្រាយដ៏មានប្រសិទ្ធភាពបំផុតនៃការអនុវត្តនេះ គឺឱ្យអ្នកនាំពាក្យនៃក្រុមនីមួយៗ ថ្លែងសេចក្ដីប្រកាសនៃការចាប់ផ្ដើម ការការពារកុមារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច។ សេចក្ដីប្រកាសរបស់គេនឹងមិនត្រូវវែង ឬលំអិតពេកទេ ប៉ុន្តែត្រូវបង្ហាញឱ្យឃើញច្បាស់នូវជំហរនៃដៃគូត្រីភាគីចំពោះបញ្ហានេះ។

*ការពិភាក្សាត្រីភាគី*

របៀបដែលនាំឱ្យការពិភាក្សាមានដំណើរទៅមុខបន្ទាប់ពីសេចក្ដីប្រកាសនៃការចាប់ផ្ដើមធ្វើការនោះ អាស្រ័យដោយអ្វីៗដែលក្រុមនីមួយៗបានរៀបចំសម្រាប់ធ្វើអនុសាសន៍។

ប៉ុន្តែការពិភាក្សាត្រូវលើកឡើងនូវអត្ថន័យរបស់កុមារបញ្ហាកាតព្វកិច្ចសិក្សាអាយុដែលអាចទទួលការងារ ហើយការងារខ្លះនាំឱ្យមានគ្រោះថ្នាក់។ ក្រុមនីមួយៗត្រូវបង្ហាញជំហររបស់ខ្លួន នយោបាយរបស់ខ្លួន មតិរបស់គេ និងអនុសាសន៍របស់ខ្លួន ចំពោះទិដ្ឋភាពនីមួយៗ។

ក្នុងលំដាប់ដែលការពិភាក្សាមានដំណើរការទៅមុខដោយប្រៀបធៀបទៅនឹងណាមួយក្នុងចំណោម ទិដ្ឋភាពទាំងនេះ សូមអនុញ្ញាតឱ្យធ្វើការផ្លាស់ប្ដូរមតិរបស់តំណាងនៃក្រុមផ្សេងៗ។ សូមអ្នកដើរតួជាអ្នកដឹកនាំការពិភាក្សា បើគេមិនចាត់តាំងអ្នកចូលរួមណាមួយឱ្យទទួលតួនាទីនេះ។ ក្រុមមួយចំនួនអាចមិនយល់ព្រម ជាមួយនឹងគោលជំហររបស់ដៃគូត្រីភាគីផ្សេងទៀតចំពោះបញ្ហាមួយចំនួន។ សូមធានាថាការព្រមព្រៀង ឬមិនព្រមព្រៀងទាំងនេះ សុទ្ធតែត្រូវបានត្រួតពិនិត្យត្រឹមត្រូវ។ ជាធម្មតាសូមកុំឱ្យការពិភាក្សាងាកចេញទៅរកការទាស់ទែងស្រែកឡូឡា ប៉ុន្តែត្រូវលើកទឹកចិត្តគេម្នាក់ៗឱ្យធ្វើអត្ថាធិប្បាយ អំពីអ្វីដែលគេបាននិយាយ និងគោលជំហរដែលគេបានប្រកាន់យក។ សកម្មភាពនេះគឺជាការបញ្ចូលការពិភាក្សាត្រីភាគី

ហើយពួកយុវជន នឹងយល់ច្បាស់ថា ក្រុមផ្សេងៗមានគោលជំហរផ្សេងគ្នា និងដោយសារអ្វីដែលគេតំណាងឱ្យ។ ឧទាហរណ៍ភាគច្រើនចំពោះបញ្ហាណាមួយដោយសារធម្មជាតិរបស់គេ និយោជកអាចពេញចិត្តចំពោះអាយុទាបបំផុត ដែលត្រូវអនុញ្ញាតឱ្យធ្វើការងារក្នុងករណីខ្លះៗ។ សហជីពនានាអាច មិនយល់ព្រមចំពោះបញ្ហានេះដោយគេចង់ ការពារមុខរបរ និងសមាជិករបស់គេ ក៏ដូចជាសុខុមាលភាពរបស់យុវជន។

កាលណាលោកអ្នកដឹងថា ថាមពល និងផលប្រយោជន៍ដែលស្ថិតនៅលើចំណុចណាមួយថយចុះពិតប្រាកដ សូមបញ្ចប់ការពិភាក្សា ហើយស្នើសុំឱ្យក្រុមបោះឆ្នោតកំណត់យកចំណុចណាមួយ នៅលើមូលដ្ឋាន នៃអំណះអំណាង ដែលពួកគេបានស្តាប់។ សូមលោកអ្នកកុំកំណត់តម្លៃផ្សេងៗគ្នាទៅឱ្យគោលជំហរនៃដៃគូត្រីភាគី និងសូមប្រាប់ទៅក្រុម ឱ្យយល់ដឹងថា គេទាំងអស់គ្នាស្មើភាពគ្នា ហើយម្នាក់ៗមានសិទ្ធិបោះឆ្នោត យ៉ាងត្រឹមត្រូវបំផុតតាមយោបល់របស់គាត់។ ដូច្នេះ ប្រសិនបើក្រុមណាមួយទាមទារអាយុអប្បបរមា ១៦ឆ្នាំឱ្យទទួលការបំរើការងារ ក្រុមមួយទៀតទាមទារអាយុ ១៨ឆ្នាំ និងក្រុមមួយទៀតទាមទារអាយុ ១៥ឆ្នាំកំណត់នៅពេលចប់ការពិភាក្សា មនុស្សភាគច្រើន នឹងនាំមកនូវការសម្តែងមតិ ហើយមតិនេះនឹងប្រែក្លាយជា "សេចក្តីសម្រេច"មួយ។ សូមពន្យល់ថា បុគ្គលនីមួយៗ មិនត្រូវបានបង្ខំឱ្យបោះឆ្នោតគាំទ្រអនុសាសន៍នៃក្រុមរបស់គាត់ផ្ទាល់ឡើយ។ គេនឹងអាចជឿក្រុមមួយទៀតតាមរយៈអំណះអំណាងរបស់គេ ហើយក៏សម្រេចគាំទ្រសំណើផ្សេងទៀតរបស់ក្រុមនោះ។ មិនចាំបាច់អញ្ជើញអាជ្ញាកណ្តាលណាមួយឱ្យមកធ្វើការវិនិច្ឆ័យពិភាក្សានេះទេ។ ត្រូវដឹងឱ្យច្បាស់ថាអ្នកណាមួយ (ខ្លួនអ្នក ឬអ្នកផ្សេងៗ) ដែលត្រូវចាត់តាំងចេញពីក្រុមមកបានកត់ត្រា ការបោះឆ្នោត និងសេចក្តីសម្រេចចិត្ត។ សូមតាមដានការពិភាក្សារហូត ដល់ពេលលោកអ្នកសន្និដ្ឋានបានថា

ពួកគេបានការចាប់អារម្មណ៍ហើយ រីឯថាមពលរបស់ក្រុមទាំងមូលត្រូវបានលើកកំពស់។ នៅពេលដែលលោកអ្នកដឹងថាការចាប់អារម្មណ៍ និងថាមពលរបស់យុវជនចាប់ផ្តើមបាត់បង់ សូមបញ្ចប់ការអនុវត្តនី ឬសូមលើកពេលនៃការអនុវត្តទៅពេលក្រោយដើម្បីឱ្យយុវជនមាន ឱកាសប្រមូលបានមកវិញនូវថាមពលរបស់គេ។

សូមលោកអ្នកគ្រប់គ្រងរយៈពេលនៃការអនុវត្តនេះឱ្យបានល្អ។ សារៈសំខាន់នឹងមានតិចតួចណាស់ ប្រសិនបើក្រុម មិនចុះសម្រុងព្រមព្រៀងគ្នា ឬការពិភាក្សាពុំបានបញ្ចប់ពេញលេញ។ អ្វីដែលសំខាន់ គឺក្រុមត្រូវយល់អំពីពិភពការងារ និងរបៀបដែលក្រុម និងក្រុមហ៊ុនសាកល្បងធ្វើការ ដើម្បីកំណត់យកទស្សនៈផ្សេងៗ និងវិស័យដែលគេចាប់អារម្មណ៍។ គេដឹងថាវាជាការពិបាកណាស់ការត្រៀមដោះស្រាយបញ្ហា កាលណាផលប្រយោជន៍ផ្សេងៗបានកើតមានឡើងយ៉ាងរឹងមាំហើយនោះ។ កិច្ចសន្ទារបស់គ្រូបង្រៀន ឬអ្នកតំណាងខាងក្រៅនឹងបង្កើនការយកចិត្តទុកដាក់របស់ក្រុមឱ្យកាន់តែខ្លាំង និងផ្តល់នូវចំណុចផ្សេងៗទៀតសម្រាប់ការពិភាក្សា និងការពិនិត្យពិច័យ ពិចារណាដែលយុវជនមិនធ្លាប់បានជួបប្រទះ។

សូមលើកទឹកចិត្តគ្រូបង្រៀន ឬអ្នកតំណាងទាំងឡាយឱ្យស្ថិតនៅជិតក្រុមក្នុងពេលពិភាក្សាត្រីភាគី ពីព្រោះយុវជននឹងត្រូវការជំនួយ និងការប្រមូលជាអតិបរមា។ ប្រធានបទត្រូវមានលក្ខណៈឱ្យគេចាប់អារម្មណ៍ និងញុាំងឱ្យមានការសប្បាយរីករាយផងដែរ។

ការពិភាក្សាអាចមានចលនាផុសផុលជាវិជ្ជមានទាំងស្រុង។ សូមកុំភ្លេចលើកទឹកចិត្តក្រុមទាំងឡាយ ឱ្យមានគំនិតច្នៃប្រឌិតឱ្យបានខ្លាំងក្លាដល់ការរៀបចំការពិភាក្សាផង។ សូមកុំយករាល់ព័ត៌មានមកដាក់លើឆាកទាំងអស់។ សូមបំផុសគំនិតរបស់គេផ្ទាល់ ចំពោះអ្វីដែលរដ្ឋាភិបាល,និយោជក ឬពលករចង់បាន និងដោយបញ្ជាក់មូលហេតុអ្វី។ គោលបំណងនៃការអនុវត្តន៍មិនទាមទារឱ្យច្បាស់លាស់បំផុត ឬឆ្លាតវៃបំផុតនោះទេ ប៉ុន្តែទាមទារឱ្យយុវជនវាយតម្លៃចូលរួមពិភាក្សា និងម្យ៉ាងទៀតឱ្យគេយល់ទស្សនៈ នៃកិច្ចព្រមព្រៀងរវាងគ្នានឹងគ្នាផង។ កាលណាយុវជនមានគំនិតច្នៃប្រឌិតកាន់តែខ្លាំងកាលណា ការធ្វើលំហាត់មានលក្ខណៈ សប្បាយ រីករាយកាន់តែខ្លាំង កាលនោះសម្រាប់គេទាំងឡាយ។

## ការត្រួតពិនិត្យជាក់ស្តែង

កាលណាការពិភាក្សាត្រូវបានបញ្ចប់ ក្រុមត្រូវធ្វើរបាយការណ៍ជាលាយល័ក្ខអក្សរមួយ ស្តីពីសកម្មភាពបន្ថែមក្នុងក្របខ័ណ្ឌនៃការអនុវត្តន៍នេះ។ សកម្មភាពបន្ថែមនេះ គឺជាការងាររបស់ក្រុមរួមបញ្ចូលទាំងការបិទក្រដាសលើជញ្ជាំងសិល្បៈ ការកសាងអក្សរសាស្ត្រសម្រាប់ការរៀបចំគម្រោងរបាយការណ៍នៃការអនុវត្ត។ ប្រសិនបើលោកអ្នកធ្វើការក្នុងបរិបទនៃការអប់រំក្នុងប្រព័ន្ធ ការងារដែលបានបញ្ចប់ហើយត្រូវតែដាក់ឱ្យគេមើលនៅកន្លែង ដែលគេអាចមើលឃើញច្បាស់ ដើម្បីជំរុញឱ្យមានការចាប់អារម្មណ៍ខ្លាំងនៅក្នុងសហគមន៍សិក្សា។ លោកអ្នកអាចបញ្ចុះបញ្ចូលក្រុម ឱ្យរៀបចំយុទ្ធការមួយដោយប្រើបណ្តាញផ្សព្វផ្សាយស្តីអំពីលំហាត់ ដោយសរសេរប្រកាសព័ត៌មាន ឬអត្ថបទសម្រាប់ផ្សព្វផ្សាយ ក្នុងទិន្នានុប្បវត្តិនៃសាលារៀន។



ទោះបីសកម្មភាពបន្ថែមនេះ អាស្រ័យដោយពេលវេលា និងព័ត៌មានដ៏សំខាន់ ក៏ដោយចុះ ក៏យើងសូមឱ្យពួកអ្នកធ្វើឱ្យបានសម្រេចនូវការងារនេះ ពីព្រោះ

វាធ្វើឱ្យយុវជនទទួល និងពង្រីកនូវចំណេះដឹងរបស់ពួកគេ។ គោលបំណងនៃសកម្មភាពនេះ គឺតម្រូវឱ្យប្រៀបធៀបលទ្ធផលនៃការពិភាក្សាត្រីភាគីទៅនឹងស្ថានភាពពិត ក្នុងប្រទេសផ្ទាល់ខ្លួនរបស់គេមួយផ្នែកនៃការងារនេះអាចត្រូវបានធ្វើរួចតាំងតែពីមុនមកហើយ.ឧទាហរណ៍ដូចជា នៅម៉ូឌុល "ស្រាវជ្រាវ និងផ្សព្វផ្សាយ"។ រឿងនេះបានសេចក្តីថា ព័ត៌មានទាំងឡាយ ដែលក្រុមត្រូវការមាននៅក្នុងដៃស្រាប់។ ជួនកាលផ្នែកណាមួយនៃព័ត៌មានទាំងនេះ ក្រុមត្រូវធ្វើការស្រាវជ្រាវ ដើម្បីរកឱ្យឃើញចម្លើយចំពោះបញ្ហារបស់គេ។

នេះជាគំនិតល្អមួយក្នុងទស្សនៈនៃការបញ្ចូលទៅក្នុងសហគមន៍ ការអញ្ជើញតំណាងរបស់ដៃគូត្រីភាគីឱ្យមកពិភាក្សាបញ្ហាទាំងអស់នេះជាមួយក្រុម គឺជាគំនិតមួយយ៉ាងល្អស្របតាមស្មារតីសមាហរណកម្មសហ-គមន៍ គោលបំណង គឺឱ្យយុវជនប្រៀបធៀបស្ថានភាពផ្លូវច្បាប់បច្ចុប្បន្នក្នុងប្រទេសរបស់គេទៅនឹងលទ្ធផលនៃការពិភាក្សាទៅនឹង "សេចក្តីសម្រេចទាំងឡាយ" ដែលគេបានធ្វើលើបញ្ហាការពារកុមារ"។

ព័ត៌មានស្តីពីបញ្ហាអាយុ អប្បបរមាដែលអាចទទួលធ្វើការងារអាយុក្នុងកាតព្វកិច្ចសិក្សាមានក្នុងការិយាល័យថ្នាក់កណ្តាល ឬថ្នាក់មូល-ដ្ឋានរបស់រដ្ឋាភិបាល។ និយោជកទាំងឡាយ ឬពលករ កម្មករទាំងឡាយអាចផ្តល់ព័ត៌មានទាំងនេះបាន។

នេះជាកិច្ចការមួយមានប្រយោជន៍ សម្រាប់ប្រៀបធៀបលទ្ធផលនៃការពិភាក្សាត្រីភាគីជាមួយនឹងខ្នាតអន្តរជាតិនៃការងារអនុម័ត ដោយអង្គការសហប្រជាជាតិនឹងអង្គការពលកម្មអន្តរជាតិ ILO ដែលត្រូវបានយកមកជជែកគ្នាក្នុងម៉ូឌុលដែលមានចំណងជើងថា "ផ្សព្វផ្សាយ"។

ការហ្វឹកហាត់នេះគប្បីនឹងប្រព្រឹត្តទៅក្នុងបរិបទនៃការពិភាក្សាទូទៅមួយ និងក្រៅផ្លូវការជាមួយក្រុមទាំងមូល។ ចូរប្រៀបធៀបលទ្ធផល

នៃការពិភាក្សាផ្ទាល់របស់ពួកគេ តាមបទដ្ឋាន (ស្តង់ដាជាតិ និង អន្តរជាតិ)។ សូមលោកអ្នកស្វែងរកនូវអ្វីដែលខុសគ្នា។ តើយុវជនវាយតម្លៃថា គោលជំហររបស់គេល្អប្រសើរសម្រាប់កុមារ ឬទេ? តើពួកគេគិតថាការតាក់តែងច្បាប់ផ្ទាល់របស់គេទន្ទឹមនឹងបទដ្ឋានអន្តរជាតិ មិនគ្រប់គ្រាន់ សម្រាប់ការពារកុមារ ឬទេ? តើគេគិតឃើញអ្វីពីការខុសគ្នានេះ?

តើគេចង់និយាយអ្វីខ្លះទេអំពីការខុសគ្នានោះ? តើគេចង់ទាក់ទងដៃគូត្រីភាគីឬទេ ចំពោះការខុសគ្នាទាំងនេះ ហើយចង់ផ្សព្វផ្សាយការអត្ថាធិប្បាយរបស់ខ្លួនគេជាសាធារណៈឬទេ? តើគេចង់សរសេរលិខិតទៅកាន់អ្នកទទួលខុសត្រូវសំខាន់ៗ និងសួរចង់ដឹងអ្វី ដែលត្រូវបានគេកំពុងធ្វើដើម្បីការពារកុមារនៅកន្លែងធ្វើការ និងប្រឆាំងការធ្វើអាជីវកម្មកុមារ ឬទេ?

ការហ្វឹកហាត់នេះអាចឃើញមានសារៈសំខាន់ណាស់ និងជាបទពិសោធន៍មួយប្រកបដោយប្រសិទ្ធភាព សម្រាប់យុវជនទាំងនេះ។ ពួកគេនឹងបានចំណេះដឹងគ្រប់គ្រាន់ ហើយពួកគេនឹងយល់ថា ការការពារកុមារក្នុងសង្គម និងរបៀបការពារកុមារ គឺសំខាន់ណាស់។ នេះគឺជាដំណាក់ការសំខាន់មួយក្នុងការអភិវឌ្ឍខ្លួនឯង និងសង្គម ហើយលោកអ្នកត្រូវលើកទឹកចិត្តពួកគេ និងគាំទ្រគេ ចំពោះសកម្មភាពផ្សេងៗទៀត ដែលគេចង់ធ្វើ។ សកម្មភាពអ្វីមួយដែលអាច សរសេរទៅកាន់អ្នកនយោបាយរបស់រដ្ឋាភិបាលកណ្តាល ឬនៅមូលដ្ឋានសរសេរទៅកាន់អង្គការ និយោជកទំនាក់ទំនងសហជីព បង្កើតយុទ្ធការមួយអម ប្រព័ន្ធផ្សព្វផ្សាយ អញ្ជើញមន្ត្រីសំខាន់ មកជជែកវែកញែកបញ្ហាទាំងនេះ ជាមួយគេទាំងអស់គ្នានៅពេលពិភាក្សាសាធារណៈ ឧទាហរណ៍ ការប្រជុំតុមូល (មើលម៉ូឌុលពិភាក្សា)។

បើពួកគេដឹងថា ខ្លួនគេមានសមត្ថភាពល្មមអាចទទួលដោះស្រាយបញ្ហាបាន សូមទុកឱ្យគេដោះស្រាយតាមសភាព និងមនោសញ្ចេតនារបស់គេ ដោយពួកគាំទ្រគេតាមដែលលោកអ្នកអាចធ្វើទៅបាន។ នេះជា

ប្រភេទនៃសកម្មភាព ដែលលោកអ្នកសង្ឃឹមថា នឹងធ្វើឱ្យដើរ ដោយសារម៉ូឌុលនេះ។

## អ្វីដែលត្រូវធ្វើ និងមិនត្រូវធ្វើ



- សូមឱ្យម្នាក់ៗចូលរួមគ្រប់ពេលប្រជុំនៃម៉ូឌុលនេះ។ វាគឺជាការអនុវត្តមួយដ៏សំខាន់បំផុត ជាពិសេស ការអនុវត្តនេះ នាំមកឱ្យយុវជននូវសញ្ញាណមួយ ចំនួនអំពីទម្រង់នៃដំណើរការរបស់ពិភពការងារ ដែលជាកន្លែងមួយដែលពួកយុវជនត្រូវឆ្លងកាត់ អស់មួយរយៈធំនៃជីវិត របស់គេ។
- សូមលើកទឹកចិត្តបន្តិចចំពោះការកំប្លែងស្លូត និង ការផ្លាស់ប្តូរគំនិតគ្នា បន្តិចបន្តួចចំពោះក្រុម ដើម្បី សម្រួលការប្រជុំ ពីព្រោះវាអាចក្លាយ ជាការធុញ ថប់ដោយសារការទទួលព័ត៌មានច្រើនពេក។
- សូមលើកទឹកចិត្តបុគ្គលនៅចំពោះមុខក្រុមឱ្យកត់ត្រា ឱ្យទទួលតួនាទី ជាអ្នកធ្វើរបាយការណ៍ ដោយ កត់ត្រាចំណុចសំខាន់ៗ ដែលត្រូវបានលើក នៅក្នុង ការពិភាក្សា។ នេះជាបទពិសោធន៍ និងសមត្ថភាព ដែលមាន ប្រយោជន៍ ក្នុងការអប់រំទូទៅរបស់គេ។
- សូមកត់ត្រានូវចំណុចសំខាន់ៗដែលត្រូវបានលើក ឡើងដោយក្រុម ឬដោយបុគ្គលម្នាក់ៗ។
- សូមប្រើការប្រជុំឱ្យបានសមស្របត្រឹមត្រូវសម្រាប់ ការអនុវត្តនេះ និងបណ្តោយឱ្យក្រុមសម្តែង មតិ ខ្លួនឯងយ៉ាងចំហ និងដោយសេរី។
- បើមានលទ្ធភាព សូមប្រើប្រាស់ម៉ាស៊ីនថតវីដេអូ ឬកុំព្យូទ័រ ជាពិសេស ក្នុងពេលធ្វើការសម្ភាសន៍ ជាយថាហេតុ ឬការពិភាក្សា។

- សូមកុំអនុវត្ត(ធ្វើលំហាត់)តាមរាល់ម៉ូឌុលទាំងអស់។ យោលទៅតាម ពេលវេលា
- ធនធាន និងការចាំបាច់ លោកអ្នកអាចប្រមើល មើល និង ជ្រើសរើសការអនុវត្តណាមួយ ក្នុងចំណោមការអនុវត្ត (លំហាត់)ដែលល្អបំផុតតាមតម្រូវការ និងកាលៈទេសៈរបស់ក្រុម។
- សូមធ្វើឱ្យប្រាកដថា ការសម្ភាសន៍ត្រូវបានពិភាក្សាដោយលំអិត រៀបចំ និងតាមដាន ដោយត្រឹមត្រូវ (មើលម៉ូឌុលសន្ទនា និងអង្កេត)។
- សូមលើកទឹកចិត្តក្រុមឱ្យធ្វើលិខិតថ្លែងអំណរគុណដល់បុគ្គលដែលបានចូលរួមកិច្ចការទាំងនេះ។
- សូមកុំនាំយុវជនណាម្នាក់ធ្លាក់ចូលក្នុងស្ថានភាពដែលនាំការទំនុកចិត្តខ្លួនឯងអាចត្រូវវិនាស ពិសេស បើគេមិនមានសមត្ថភាពអនុវត្តការសម្ភាសន៍មួយ ឬដើម្បីដើរតួយ៉ាងសំខាន់ប្រកបដោយឧត្តមភាព ដូចជា ការនាំពាក្យនៃក្រុមជាដើម។



- សមាជិកក្រុមម្នាក់ៗត្រូវរកឱ្យឃើញនូវតួនាទីរបស់ខ្លួនក្នុងការអនុវត្តទាំងនេះ។ សូមគាំទ្រដំណើរការនេះនិងធ្វើឱ្យយុវជនទាំងឡាយមានដំណើរការល្អក្នុងតួនាទីរបស់ខ្លួន។
- សូមឱ្យប្រុងប្រយ័ត្នសមាជិកក្រុម បានចូលក្នុងសកម្មភាពនៃការស្រាវជ្រាវ ដូចជាសរសេរលិខិតជាដើម ដោយហេតុរឿងនេះនឹងផ្តល់សមត្ថភាពបុគ្គល សមត្ថភាពសង្គម និងសមត្ថភាពទំនាក់ទំនង។
- សូមកុំឱ្យកិច្ចការទាំងឡាយ ប្រែក្លាយជា ការប្រកួតប្រជែង ជ្រុលពេក។

- សូមលោកអ្នកអានឱ្យខ្លាំងៗនូវសម្រង់អត្ថបទចេញពីគ្រប់ការងារទាំងអស់ ហើយលោកអ្នកអាន មិនត្រឹមតែអ្វី ដែលលោកអ្នកវាយតម្លៃថា ល្អណាស់ ឬសមហេតុសមផលបំផុតនោះទេ។ ការងារ និងទស្សនៈនៃបុគ្គលម្នាក់ៗត្រូវតែគិតគូរទទួលយក ហើយយុវជនទាំងឡាយនឹងចាត់ទុក លោកអ្នកថា ជាអ្នកត្រឹមត្រូវ។
- សូមកុំអនុញ្ញាតឱ្យពួកយុវជនដែលចំអកចំពោះការងារដែលធ្វើរួចហើយ ឬចំពោះអ្នកដែលចូលរួម ក្នុងការប្រជុំសន្និនារបស់សង្គម។
- សូមគាំទ្រ និងលើកទឹកចិត្តទាំងស្រុងដល់ក្រុម ដែលសម្រេចចិត្តទទួលធ្វើសកម្មភាព បន្ទាប់ពីការពិភាក្សាត្រីភាគី។ ការគាំទ្រ និងការលើកទឹកចិត្តរបស់អ្នកមានសារៈសំខាន់ណាស់សម្រាប់គេទាំងឡាយ ហើយនិងបង្កើនកម្លាំងថែមទៀត ទៅលើការទុកចិត្ត ដែលលោកអ្នក បានគិតថាឱ្យមាន នៅក្នុងក្រុម។

## ការពិភាក្សាបញ្ចប់

*បង្រៀន១ពេល*



នៅពេលការអនុវត្តត្រូវបានបញ្ចប់ សូមប្រមូលក្រុមទៅប្រជុំក្នុងបន្ទប់ប្រជុំរបស់គេ ឬតាមទម្លាប់នៅក្នុង ថ្នាក់ និងសូមធ្វើយ៉ាងណាឱ្យបរិយាកាសបានធូរស្រាល និងសប្បាយរីករាយ។ វត្តមាននៃធនធានមនុស្ស ពីខាងក្រៅជាការចាំបាច់ ប្រសិនបើលទ្ធភាពអញ្ជើញ។ បើករៀបចំនូវសម្ភារដែលបានមកពីការអនុវត្តដែលធ្វើនៅចំពោះមុខអ្នក ទោះបីការងាររបាយការណ៍ បទសម្ភាសន៍ វីដេអូ ឬលទ្ធផលនៃការពិភាក្សាត្រីភាគីក៏ដោយ។

សូមនិយាយអំពីដំណើរការដែលក្រុមត្រូវទទួលយក និងសូមចាប់ផ្តើមធ្វើការពិភាក្សាទូទៅមួយ ស្តីអំពីទិដ្ឋភាពនីមួយៗ នៃការអនុវត្តនចាប់តាំងពីការរៀបចំ ការតាក់តែងគម្រោងនានា រហូតដល់ការធ្វើសកម្មភាព និងការធ្វើការតាមដាន។ សូមពិនិត្យអ្វីដែលយុវជនបានវាយតម្លៃច្រើនជាងគេ ផ្ទុយទៅវិញអ្វីដែលគេអបអរសាទរតិចបំផុត។ សូមផ្តល់ឱ្យគេនូវលទ្ធភាពបញ្ចេញយោបល់ ដោយសេរី និងដោយចំហចំពោះបញ្ហាណាមួយ។ សូមផ្តល់ឱ្យពួកគេនូវសេរីភាពខាងនិយាយ និងបញ្ចេញយោបល់ជាបន្តបន្ទាប់រហូតដល់គម្រោងចម្រើនឈានទៅមុខ។

វិធីនឹងផ្តល់សេចក្តីទុកចិត្ត និងពង្រឹងចំណងសាមគ្គីភាពនៅក្នុងក្រុមបាន។ ការពិភាក្សាចុងក្រោយ អំពីសៀវភៅនេះនឹងត្រូវបញ្ចប់ ហើយមានសារៈសំខាន់ណាស់ម៉ូឌុល "ពិភពការងារ" គឺជាសមាសភាគមួយដ៏សំខាន់ ដែលធ្វើឱ្យយុវជនចាប់អារម្មណ៍ ចំពោះពលកម្មកុមារ។ សៀវភៅនេះជួយយុវជន ឱ្យបញ្ចូលបញ្ហាទៅក្នុងបរិបទរបស់គេ និងឱ្យពួកគេយល់ច្បាស់នូវ "មូលហេតុ"នៃពលកម្មកុមារ និងរបៀបការពារកុមារឱ្យបានល្អ។ ដោយសារការពិភាក្សាត្រីភាគីយុវជនយល់ដឹងអំពីភាពស្មុគ្រស្មាញនៃ "ពិភពការងារ" និង

របៀបដែលក្រុមនីមួយៗ (រដ្ឋាភិបាល និយោជក និងអ្នកធ្វើការងារ) បង្កើតបញ្ហាមួយផ្នែក ក៏ប៉ុន្តែអាចផ្តល់ដំណោះស្រាយមួយផ្នែកផងដែរ។

សូមក្រឡេកមើលផ្នែកពិភាក្សានៅចុងបញ្ចប់ម៉ូឌុល "សន្ទនា និងអង្កេត" ម៉ូឌុល "ស្រាវជ្រាវ និង ផ្សព្វផ្សាយ" ហើយនិងម៉ូឌុលពិភាក្សា"។ សៀវភៅទាំងអស់នេះមានព័ត៌មានដែលមានប្រយោជន៍ច្រើនសម្រាប់ ការពិភាក្សានៅបញ្ចប់ ម៉ូឌុលនេះ។

## ការវាយតម្លៃ សកម្មភាពបន្ត



អ្វីដែលទាក់ទងនឹងអាំងឌីកាទ័រ ដែលអាចប៉ាន់ប្រមាណបានក្នុងក្របខណ្ឌ នៃម៉ូឌុលនេះ។លទ្ធផលពិតប្រាកដជាក់លាក់ដែលអាចប្រមាណប្រាកដជាមានពិតប្រាកដ។ ទៅតាមការអនុវត្តដែលលោកអ្នកសម្រេចចិត្តធ្វើ,ក្រុមទាំងអស់នឹងធ្វើឱ្យសម្រេចការងារនោះ ដោយធ្វើការសម្ភាសន៍មួយ និងដឹកនាំបានល្អនូវការពិភាក្សាមួយស្តីពីបញ្ហាពលកម្មកុមារ។

អាំងឌីកាទ័រមួយចំនួនក្នុងម៉ូឌុលនេះ សម្រាប់រយៈពេលខ្លីមិនសូវប្រត្យក្សទេ។ ជោគជ័យនៃម៉ូឌុលនេះនឹងបង្ហាញឱ្យឃើញដោយសារតែការចម្រើនរបស់បុគ្គលតាមរយៈការប្រើប្រាស់ម៉ូឌុលផ្សេងៗទៀតតែប៉ុណ្ណោះ។ ការពិភាក្សាត្រីភាគី អាចបង្ហាញឱ្យឃើញនូវវិធីមួយដ៏មានប្រយោជន៍ស្វាហាប់ និងពោរពេញទៅដោយថាមពល។

ម៉ូឌុលនេះផ្តល់លទ្ធភាពដល់យុវជនឱ្យបើកនូវមធ្យោបាយទំនាក់ទំនងជាមួយរដ្ឋាភិបាល អង្គការ និយោជក ហើយនឹងអ្នកធ្វើការងារ។ នេះជារឿងសំខាន់បង្គួរចាប់តាំងពីបច្ចុប្បន្ន ហើយអាចមានការទាក់ទងយ៉ាងសំខាន់ថែមទៀតជាបណ្តើរៗតាមលំដាប់

ដែលយុវជនមានការរីកចំរើនក្នុងឋានៈជាបុគ្គលហើយចេះពិចារណាលើអនាគតផ្ទាល់ខ្លួន ផ្នែកខាងការសិក្សាក៏ដូចជាខាងមុខរបរ។ ចំណែកការអភិវឌ្ឍខ្លួនផ្ទាល់ និងសមត្ថភាពក្នុងសង្គម,គេត្រូវការឱកាស រៀនសូត្រមួយយ៉ាងសំខាន់។ ម៉ូឌុលនេះធ្វើឱ្យយុវជនមានការ ទទួលខុសត្រូវកាន់តែខ្ពស់ឡើង។

ដោយឃើញថា យុវជនទទួលរ៉ាប់រងតួនាទីនៃមនុស្ស និងអ្នកជំនាញសំខាន់ៗដោយព្យាយាមគិតពិចារណា និងប្រកាន់យក គោលជំហរដៃមនុស្សទាំងអស់នោះប្រកាន់យក។ ម៉ូឌុលនេះ ជួយឱ្យយល់អ្វីដែលរដ្ឋាភិបាល អង្គការ និយោជក និងអ្នកធ្វើការងារ អាចធ្វើចំពោះយុទ្ធការពិភពលោក ដើម្បីលុបបំបាត់ពលកម្មកុមារ។

នៅពេលដែលអ្នកបានបញ្ចប់ម៉ូឌុលនេះដោយពេញចិត្តរបស់អ្នក សូមអ្នកឆ្លងទៅម៉ូឌុលថ្មីទៀត។ ប្រសិនបើ អ្នកមិនទាន់បានអនុវត្តម៉ូឌុលផ្សព្វផ្សាយទាំងពីរនៅឡើយ, យើងសូមណែនាំអ្នក ឱ្យអនុវត្តម៉ូឌុលនោះទៅទៀត។ ម្យ៉ាងទៀត អ្នកគួរប្រមើលមើល ហើយអនុវត្តល្បែងដើរតួ (លេងរឿង) ឬសម្ដែងល្ខោន។

# ឧបសម្ព័ន្ធ១

## ការពិចារណាសម្រាប់ក្រុមត្រីភាគីក្នុងលំហាត់ពិភាក្សា

### *ក្រុមតំណាងរដ្ឋាភិបាល*

ផលប្រយោជន៍សំខាន់ៗរបស់ក្រុមនេះមាន :

- ការតាក់តែងច្បាប់ ច្បាប់ទាំងឡាយចាំបាច់ណាស់សម្រាប់ប្រទេសមួយ ដើម្បីការពារមនុស្ស, គ្រប់គ្រងសេដ្ឋកិច្ច,ការពារមនុស្សដែលធ្វើការងារ ការពារកុមារ, ចាត់វិធានការ ដើម្បីឱ្យសង្គមរីកចំរើនក្នុង ក្របខ័ណ្ឌមួយនៃការរួបរួមសង្គម ។
- សេវាកម្មសាធារណៈ តើសេវាកម្មអ្វីខ្លះដែលរដ្ឋាភិបាលផ្ដល់ឱ្យប្រជាជនរបស់ខ្លួន? សុខភាព? ការអប់រំ? ការដឹកជញ្ជូន? តើសេវាកម្មទាំងនេះសុទ្ធតែផ្ដល់ប្រាក់ឬ? តើគេបានបែងចែកដូចម្ដេចខ្លះ? តើគេទាំងអស់គ្នា មានសិទ្ធិក្នុងការអប់រំ? រដ្ឋាភិបាលត្រូវរ៉ាប់រងការអប់រំមួយ ដោយឥតបង់ថ្លៃសម្រាប់ទាំងអស់គ្នាឬ? តើគេអាចធ្វើតាមអំពើចិត្តខ្លួនឬ? តើគេអាចមិនធ្វើតាមអំពើចិត្តខ្លួនឬ? តើពលរដ្ឋត្រូវចំណាយប្រាក់ទៅលើអ្វីៗ ខ្លះឬ? ប្រព័ន្ធសុខាភិបាលត្រូវបង់ថ្លៃ ឬមិនបង់ថ្លៃ? តើរដ្ឋាភិបាលមាននយោបាយ ដើម្បីផ្ដល់ជូនសេវាកម្មសាធារណៈប្រកបដោយគុណភាពឬទេ?
- សុខមាលភាពសង្គម : តើរដ្ឋាភិបាលថែទាំប្រជាជនក្រីក្រយ៉ាងដូចម្ដេច? តើភាពក្រីក្រត្រូវបានគ្រប់គ្រងឬទេ? តើរដ្ឋាភិបាលមាននយោបាយគាំទ្ររដ្ឋឱ្យមានសុខមាលភាពឬទេ? តើលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ដែលចាត់ទុកជាជំនួយរបស់រដ្ឋាភិបាល? តើរដ្ឋាភិបាលមានយកចិត្តទុកដាក់ឬទេចំពោះការ កើនឡើង នៃប្រជាជន? តើធ្វើដូចម្ដេច?
- ការធ្វើផែនការ : តើមានទីក្រុងធំៗក្នុងប្រទេសនេះឬទេ? តើក្រុងទាំងនោះត្រូវបានត្រួតពិនិត្យត្រឹមត្រូវឬទេ? តើក្រុមទាំងនោះត្រូវបានត្រួតពិនិត្យត្រឹមត្រូវឬទេ និងផែនការក្រុងដ៏មានប្រសិទ្ធភាពឬទេ? មនុស្សនៃតំបន់ជនបទ ចាកចេញទៅរស់នៅទីក្រុងឬទេ? ហេតុអ្វី? តើគេអាចធ្វើអ្វីបានខ្លះ ដើម្បីបន្ថយល្បឿននៃដំណើរនេះបានទេ? ។ តើរដ្ឋាភិបាលអាចធ្វើវិនិយោគក្នុងការអភិវឌ្ឍន៍ជនបទដើម្បីបញ្ចុះបញ្ចូលមនុស្សឱ្យនៅជនបទឬទេ? តើផែនការផ្សារភ្ជាប់ទៅនឹងការដឹកជញ្ជូន និងសេវាកម្មសាធារណដូចម្ដេច?តើមានសាលា និងគ្រូបង្រៀនគ្រប់គ្រាន់ឬទេ ក្នុងតំបន់ជនបទ?
- ប្រភេទនៃរដ្ឋាភិបាល : តើអ្វីទាំងអស់បានត្រួតពិនិត្យគ្រប់គ្រង និងផ្ដល់ប្រាក់កាសដោយ រដ្ឋាភិបាលកណ្ដាលឬទេ? ឬក៏តើរដ្ឋាភិបាលត្រូវបានវាយតម្លៃថា មានប្រជាធិបតេយ្យច្រើនជាងមុន យុត្តិធម៌

ជាងមុន និងមានប្រសិទ្ធភាពជាងមុនក្នុងការធ្វើវិមជ្ឈការរចនាសម្ព័ន្ធរបស់ខ្លួន និងអនុញ្ញាតឱ្យអាជ្ញាធរ នៅតាមតំបន់គ្រប់គ្រងបញ្ហាផ្ទាល់របស់ខ្លួន តាមយុត្តាធិការរបស់គេ? ប្រសិនជាត្រូវធ្វើ តើរដ្ឋាភិបាល ត្រួតពិនិត្យអាជ្ញាធរតំបន់ ឬអាជ្ញាធរតំបន់ត្រូវដឹកនាំដោយអ្នកនយោបាយបែបប្រជាធិបតេយ្យ ដែលត្រូវបានជ្រើសរើសសម្រាប់ដឹកនាំសកម្មភាពនៃតំបន់ណាឬទេ?

- ឧទាហរណ៍ តើពួកគេត្រួតពិនិត្យនូវអ្វីដែលកើតឡើងនៅកន្លែងធ្វើការ,ផ្នែកខាងអប់រំ និងផ្នែកផ្សេងៗ ទៀតដែរ ឬទេ?
- សិទ្ធិរបស់ប្រជាពលរដ្ឋ,សេរីភាព និងសិទ្ធិមនុស្ស តើរដ្ឋាភិបាលមានបំណង ប្រមូលបុគ្គលទាំងឡាយឱ្យរួបរួមគ្នាដោយប្រកាសថា គេនឹងគោរពទាំងស្រុងរាល់សិទ្ធិរបស់មនុស្ស រាប់បញ្ចូលទាំង សិទ្ធិកុមារផងដែរ? អ្នកធ្វើការងារអាចទទួលផលចំណេញ អំពីសិទ្ធិសហជីពរបស់ខ្លួនឬទេ? តើទៅដល់ចំណុចណា ទើបលទ្ធិប្រជាធិបតេយ្យពិតប្រាកដ? តើក្នុងតម្លៃណា?

**ក្រុមនិយោជក**

ផលប្រយោជន៍សំខាន់ៗនៃក្រុមនេះមាន ៖

- ការតាក់តែងច្បាប់តើច្បាប់អ្វីខ្លះដែលនិយោជកចង់បាន ដើម្បីគ្រប់គ្រងវិស័យនានា ដូចជា អាយុរបស់អ្នកធ្វើការងារ? តើគេចង់សាកល្បងបំពេញសិទ្ធិរបស់អ្នកធ្វើការងារមិនឱ្យបង្កើតសហជីព និងមិនឱ្យប្រាក់បៀវត្សយ៉ាងខ្ពស់ ឬលក្ខខណ្ឌដ៏ល្អប្រសើរនៃការងារឬ? តើមានប្រតិកម្មអ្វីខ្លះ ពីសំណាក់និយោជកនៅពេលមានអធិការកិច្ចនៃការងារប្រកបដោយលទ្ធផល និងប្រសិទ្ធភាពខ្ពស់? តើគេទទួលឬទេ ច្បាប់ដ៏ល្អប្រពៃដែលការពារកុមារ និងយុវជន?
- ការទទួលខុសត្រូវសង្គម តើនិយោជកនឹងធ្វើវិនិយោគដើម្បីផលប្រយោជន៍របស់ខ្លួនក្នុងវិស័យផ្សេងៗដូចជា ការសង់សាលារៀន ការអភិវឌ្ឍន៍សហគមន៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការបង្កើតការងារ ការលុបបំបាត់កាកសំណល់ ការការពារបរិស្ថាន ។ល។ តើនិយោជក ត្រូវមានការទទួល ខុសត្រូវសង្គមខ្លាំងដែរឬទេ? តើគេអាចវាយតម្លៃថា អ្វីដែលនឹងកើតឡើងក្នុងសង្គមគឺទាក់ទងនឹងខ្លួនគេឬទេ?
- ឯកជន និងសេវាកម្មសាធារណៈ តើនិយោជកពេញចិត្ត និងបង្កើតឱ្យមានសេវាកម្មសាធារណៈប្រកបដោយគុណភាពឬទេ? ផ្តល់ថវិកាដោយប្រើប្រាស់វិភាគទាន ហើយគ្រប់គ្រងដោយរដ្ឋាភិបាលមួយ ដែលអាចពន្យល់ដល់សាធារណជននូវសេចក្តីសម្រេចចិត្តរបស់ខ្លួន ដោយបង្ហាញហេតុផលច្បាស់លាស់ឬទេ? តើគេពេញចិត្តគ្រប់គ្រងសេវាកម្មទាំងនេះដោយខ្លួនគេផ្ទាល់ និងបង្កើតសហគ្រាសផ្តល់ផលដោយប្រើចំណាយមិនច្រើនពេកសម្រាប់ដំណើរការឬទេ? តើនិយោជកពេញចិត្តឬទេ នៅពេលឃើញ

សេវាកម្មសាធារណៈ ត្រូវបានដាក់ឱ្យឯកជនអនុវត្ត និងត្រូវបានដាក់ឱ្យឃើញដេញថ្លៃលើទីផ្សារ ដើម្បី រកអ្នកហ៊ានថ្លៃខ្ពស់ជាងគេ? តើគេនឹងដឹកនាំសេវាកម្ម ទាំងនេះជាបន្តទៅទៀតដូចម្តេច? ឧទាហរណ៍ តើគេជឿថាសេវាកម្មអប់រំ នឹងត្រូវផ្ញើទៅឱ្យឯកជន ឬត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវនៃរដ្ឋាភិ បាលដដែល ឬនៅពេលខាងមុខ?

សន្តិសុខសង្គមចូររួមវិភាគទាន ចំពោះសោធននិវត្តន៍ និងចំពោះពិការភាព ចំពោះអ្នកលំហែមាតុភាព ចំពោះថ្លៃឈ្នួលសិក្សារបស់កុមារ និងអ្នកធ្វើការងារ ។ល។ មានតម្លៃជាប្រាក់។ រួមវិភាគទានចំពោះផែនការសុខភាពរបស់រដ្ឋាភិបាល ដើម្បីឱ្យមនុស្សទាំងឡាយមានជំនួយផ្នែកខាងពេទ្យ ក៏មានតម្លៃជាប្រាក់ដែរ។

តើនិយោជកទាំងអស់គិតថា គេនឹងត្រូវចំណាយទាំងមូលមួយផ្នែកនៃវិភាគទាន សម្រាប់ផែនការសន្តិសុខសង្គម ក៏ដូចជាសម្រាប់អ្នកធ្វើការងាររបស់ខ្លួនឬទេ? ឬមួយអ្នកធ្វើការទាំងអស់ត្រូវផ្តល់ប្រាក់ទាំងនេះពីហោប៉ៅរបស់ខ្លួនផ្ទាល់? តើនិយោជកទាំងអស់ចង់រៀបចំសោធនផ្ទាល់ខ្លួនសម្រាប់កម្មករចូលនិវត្តន៍ ឬចូលរួមផ្តល់ប្រាក់វិភាគទានដល់សោធនរបស់រដ្ឋ? តើគេនឹងជួយកម្មករដែលខ្វះអំណោយផលដោយផ្តល់សេវាកម្មខ្លះដូចជាៈ បង្កើតទារកដ្ឋានសម្រាប់ជួយកម្មការិនី ការបណ្តុះបណ្តាល បណ្តាល សម្រាប់អ្នកធ្វើការងារដើម្បីបង្កើនការឯកភាពវិជ្ជាជីវៈ ការព្រមព្រៀងឱ្យអ្នកធ្វើការងារខ្ចីប្រាក់ព្រោះពួកគេមិនអាចអត្រាការប្រាក់នៃធនាគារបានហើយ ។ល។?

តើតម្លៃសង្គមអ្វីខ្លះដែលជាទំនួលខុសត្រូវ របស់និយោជក? តើគេសង្ឃឹមថា និយោជក នឹងថែទាំអ្នកធ្វើការងារសហគមន៍ បរិស្ថាននៃប្រទេសរបស់គេ ឬទេ?

- សិទ្ធិរបស់អ្នកធ្វើការងារ និងសិទ្ធិរបស់និយោជកតើគេអាចធ្វើឱ្យខូចប្រយោជន៍របស់និយោជក ឬទេ បើអ្នកធ្វើការងារក្លាយជាសមាជិក ឬតំណាងសហជីពដែលខ្លាំងពូកែ និងអាចផ្តល់ឥទ្ធិពលដល់មតិសាធារណជន និងរដ្ឋាភិបាល? តើនិយោជកគិតដូចម្តេចចំពោះសិទ្ធិ និង សេរីភាពបុគ្គល? តើសិទ្ធិទាំងនេះត្រូវអនុម័ត និងដាក់ឱ្យទាំងអស់គ្នាឬទេ? តើសិទ្ធិទាំងនេះត្រូវកំណត់ក្នុងករណីជាច្រើនឬទេ? តើអ្នកណាធ្វើការសម្រេចចិត្ត? តើនិយោជកទាំងអស់ រីករាយនឹងប្រើសិទ្ធិរបស់គាត់ ឬទេ? តើអ្នកដទៃទៀតមានលទ្ធភាព បញ្ចេញសំឡេងចំពោះ អ្វីដែលទាក់ទងនឹងសិទ្ធិរបស់និយោជក ឬទេ? ហេតុអ្វី? និងចំពោះអ្វីដែលទាក់ទងនឹងរដ្ឋាភិបាលឬទេ? តើគេត្រូវតែគោរពច្បាប់ និងបទបញ្ជាទាំងឡាយសម្រាប់និយោជក ហើយនិងសេរីភាព ដែលនិយោជកប្រាថ្នាចង់បានប្រហែលជាត្រូវការកាត់បន្ថយខ្លះឬទេ?

- ការរៀបចំតើនិយោជកទាំងអស់រួបរួមគ្នា ឬទេ ដើម្បីការពារផលប្រយោជន៍របស់ខ្លួន? តើគាត់ជឿជាក់ថា ពួកគេអាចធ្វើការចរចារជាមួយរដ្ឋាភិបាល និងជាមួយអ្នកធ្វើការងារ ដោយរក្សាគោលជំហររបស់ខ្លួនបានឬទេ? ពួកគេគិតថា នឹងមានកម្លាំងខ្លាំង ប្រសិនបើគេបង្កើតសហជីពមួយ ដែលតំណាងឱ្យនិយោជកទាំងអស់ ដែលនឹងបង្កើតក្រុមមួយដ៏មានឥទ្ធិពលក្នុងការបញ្ចុះបញ្ចូល ឱ្យមានការគាំទ្រដល់ពួកគេ។

## ក្រុមកម្មករ

ផលប្រយោជន៍សំខាន់ៗនៃក្រុមនេះមាន :

- ការទទួលខុសត្រូវ រចនាសម្ព័ន្ធរបស់សហព័ន្ធពាណិជ្ជកម្ម តើសហព័ន្ធពាណិជ្ជកម្មមានតួនាទីដូចម្តេច? អ្នកណាតំណាងឱ្យសហព័ន្ធពាណិជ្ជកម្ម? សមាជិកសហព័ន្ធ គឺជាមនុស្សទាំងអស់ដែលចុះឈ្មោះ និងទទួលផលចំណេញ ពីសេវាកម្ម របស់គេឬ? ឬពួកគេធ្វើការដើម្បីគ្រួសារនៃសមាជិករបស់គេ? តើពួកគេជាប់ចិត្តទៅដល់បញ្ហាផ្សេងៗទៀតក្រៅពីបញ្ហាដែលទាក់ទងការងារឬ? តើពួកគេជាប់ចិត្តទៅនឹងបញ្ហាទាំងឡាយ ដែលផ្សារភ្ជាប់ទៅនឹងបរិស្ថានទៅនឹងមនុស្សទាំងឡាយ ដែលមិនត្រូវបានគេឱ្យតម្លៃ និងគ្មានការការពារឬ? តើគេមានតួនាទីមួយក្នុងសង្គម និងការពារសង្គម ដោយធានាឱ្យសង្គមមានការរីកចំរើន និងប្រកបដោយប្រសិទ្ធភាពឬ? តើអ្វីជាប្រភពនៃប្រាក់ចំណូលរបស់គេ? តើអ្នកណាចេញប្រាក់ចំណាយ និងប្រាក់ បៀវត្សឱ្យពួកគេ? តើមានសារៈសំខាន់អ្វីចំពោះបញ្ហានេះ ពាក់ព័ន្ធនឹងឯករាជ្យភាពរបស់គេ? តើ សមាជិកទាំងអស់នឹងច្បាប់ដែលពួកគាត់នូវអ្វីដែលពួកគាត់ត្រូវធ្វើ ឬពួកគាត់ត្រូវប្រាប់ដល់សមាជិក ទាំងអស់នូវអ្វីដែលគេត្រូវធ្វើឬ?
  តើពួកគាត់ទទួលប្រាក់ជំនួយឧបត្ថម្ភពីរដ្ឋាភិបាល ឬពីនិយោជក? ហេតុអ្វី? ដោយរបៀបណា? តើរឿងនេះមានន័យថា រដ្ឋាភិបាល និងនិយោជកមានពាក្យនិយាយពន្យល់អំពីអ្វីដែលគេធ្វើ និងរបៀបដែលគេធ្វើឬ?

- ការតាក់តែងច្បាប់ សហជីពទាំងឡាយធ្វើការដើម្បីឱ្យច្បាប់ត្រូវបានអនុវត្ត ដើម្បីការពារសមាជិក និងគ្រួសាររបស់គេ.ដែលងាយរងគ្រោះនៃសង្គមការពារបរិស្ថាន និងការធានាលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សជាមូលដ្ឋាន។ គេមិនចង់ឱ្យមានក្រុមណាមួយទៀតមានអំណាចខ្លាំង អាចបង្កើតច្បាប់ដែលបម្រើតែសេចក្តីត្រូវការ និងឆន្ទៈរបស់គេប៉ុណ្ណោះ គេចង់ប្រើប្រាស់អំណាច ដែលអាចទប់ទល់របស់រដ្ឋាភិបាល និងនិយោជកបាន។ តើវាជាការសំខាន់ឬ? ការកំណត់ព្រំដែនអាយុស្របច្បាប់ សម្រាប់យុវជនដើម្បីបម្រើការងារ? តើព្រំដែនអាយុនេះជាអ្វី? តើពួកយុវជនត្រូវតែមានលទ្ធភាពធ្វើការពេលយប់ក្នុងរយៈពេលយ៉ាងវែង ទទួលប្រាក់បៀវត្សទាបបំផុត ឬធ្វើការងារដែលអាចឱ្យមានរបួស

ស្នាមឬអាចឱ្យស្លាប់ឬ? តើការងារអ្វីខ្លះ ដែលធ្វើឱ្យស្មារតី និងសីលធម៌របស់យុវជនរងឥទ្ធិពល? តើសហជីពការពារយុវជនទាំងនេះដូចម្តេច? តើសហជីពត្រូវសន្យាអ្វីដែរឬទេ? តើអាយុដែលយុវជនចាប់ផ្តើមធ្វើការងារ ត្រូវរួមបញ្ចូលជាមួយអាយុនៃកាតព្វកិច្ចសិក្សាឬទេ? ដូច្នេះ,តើរដ្ឋាភិបាល ធ្វើតុល្យភាពឬទេ ចំពោះបញ្ហាទាំងពីរ? តើមានការដាក់វិន័យ ឬទេចំពោះនិយោជកដែលធ្វើអាជីវកម្មលើកុមារ និងតើរដ្ឋាភិបាល និងសហជីពអាចត្រួតពិនិត្យស្ថានភាពនេះឬទេ? តើកត្តាអ្វីខ្លះទៀតដែលគេត្រូវយកចិត្តទុកដាក់ក្នុងករណីដែលកុមារធ្វើការងារ?

- ការទទួលខុសត្រូវសង្គម សង្គមត្រូវតែអភិវឌ្ឍ។ រដ្ឋាភិបាល និងនិយោជកត្រូវតែចូលរួមវិភាគទានចំពោះការអភិវឌ្ឍន៍សង្គម។ ប្រសិនបើក្រុមហ៊ុនណាមួយបានចំណេញប្រាក់ច្រើន ដោយសារការបង្កើតរោងចក្រដ៏ធំមួយក្នុងទីក្រុង វាជាការមិនត្រឹមត្រូវទេ ឬការសុំឱ្យក្រុមហ៊ុននេះ ផ្តល់វិភាគទាន ដើម្បីធ្វើការអភិវឌ្ឍន៍ទីក្រុងនោះ និងជាគុណប្រយោជន៍ដល់ប្រជាពលរដ្ឋរបស់ខ្លួននោះ? ក្រុមហ៊ុនអាចជួយសង់សាលារៀនអាចរ៉ាប់រងថា គេនឹងមិនបំផ្លាញបរិស្ថាន អាចចូលរួមវិភាគទាន ក្នុងការកែលំអ នៃបរិស្ថានឬទេ? តើគ្មានអ្នកណាម្នាក់រ៉ាប់រងការទទួលខុត្រូវចំពោះការការពារមនុស្សទាំងឡាយ ជាអាទិ៍ប្រជាជនដែលងាយរងគ្រោះក្នុងសង្គម កុមារស្ត្រី មនុស្សមានវ័យច្រើន ជនពិការ អ្នកជំងឺ និងអ្នកក្រីក្រទេឬ? តើសហជីពត្រូវរ៉ាប់រងតួនាទីមួយក្នុងការទទួលខុសត្រូវចំពោះសង្គមឬទេ? នៅទីបំផុត ផលប្រយោជន៍មូលដ្ឋានរបស់សហជីពតម្រូវឱ្យជួយសមាជិករបស់គេ និងកែលំអ លក្ខខណ្ឌការងាររបស់គេ។

នេះគឺជារឿងដែលមិនបណ្តោយឱ្យសហជីពគិតដល់បញ្ហាផ្សេងទៀត? ប៉ុន្តែ បើសហជីព មិនធ្វើការងារនេះ តើអ្នកណាជាអ្នកធ្វើ? តើរដ្ឋាភិបាលឬនិយោជក?

ឯករាជ្យភាពខាងនយោបាយ និងថវិកា តើសហជីពត្រូវតែឯករាជ្យទាំងស្រុងនៅចំពោះនយោបាយឬ? តើគេត្រូវអនុញ្ញាតឱ្យរដ្ឋាភិបាល និងនិយោជកទាក់ទងគ្នាក្នុងការដឹកនាំ និងគ្រប់គ្រងបញ្ហារបស់គេឬទេ? តើសហជីពត្រូវទទួលវិភាគទានជាប្រាក់កាសពីរដ្ឋាភិបាល គណបក្សនយោបាយ ឬនិយោជកឬទេ? តើអ្នកចូលក្នុងសហជីពត្រូវតែ ជ្រើសរើសដោយសមាជិក ឬចាត់តាំងដោយ ក្រុមតូចជាងគេបំផុតចំពោះសហជីព? តើសហជីពមួយអាចធានាឯករាជ្យភាពរបស់ខ្លួន និងបង្ការបាតុភូតទាំងឡាយ និងអំពើពុករលួយឬទេ?

- *សេវាកម្មសាធារណៈ* តើវិធានការណាដែលសំខាន់ សម្រាប់សហជីពដែលរដ្ឋាភិបាល រ៉ាប់រង សេវាកម្មសាធារណៈដែលមានគុណភាព? តើសហជីពរៀបចំអ្នកធ្វើការងារក្នុងសេវាសាធារណៈ ដូចជា មន្ត្រីនៅថ្នាក់ជាតិ និងមូលដ្ឋាន? តើអ្នកណាបានចំណេញ អំពីសេវាកម្មសាធារណៈ ប្រកបដោយគុណភាព? តើពួកគេបញ្ចេញអនុភាពទៅលើសេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាលដូចម្តេច? ក៏ដូចជារាំងស្កាត់ការកៀបសង្កត់រដ្ឋាភិបាលដោយពួកនិយោជក? តើសហជីពនឹងធ្វើការគាំទ្រឬទេចំពោះឯកជនកម្ម? តើមានឬទេអំណះអំណាងដ៏ល្អ ចំពោះសេរីភាវូបណីកម្មទីផ្សារ តើគេត្រូវអនុវត្តអំណះអំណាងនោះដែរឬទេ? ចំពោះសេវាកម្មសាធារណៈ? តើអ្នកជាអ្នកចំណាយប្រាក់សម្រាប់សេវាកម្មសាធារណៈ? តើអ្នកជាអ្នកចំណាយប្រាក់សម្រាប់សេវាកម្មសាធារណៈ និងតើអ្នកណាធ្វើសេចក្តីសម្រេចចិត្តក្នុងការតម្រង់ទិស ការគ្រប់គ្រង ការបែងចែកសេវាកម្មសាធារណៈឬ?
- *សុខុមាលភាពសង្គម* តើសហព័ន្ធពាណិជ្ជកម្មត្រូវតែចោទសួរដល់ខ្លួនឯងថា អ្នកណាដែលចំណាយទៅលើសោធនសុខភាព អប់រំប្រាក់បំណាច់ចំពោះអ្នកគ្មានការងារធ្វើ ការសម្រាកព្យាបាលជំងឺ និងការលំហែមាតុភាពដែរឬទេ? តើបញ្ហាទាំងនេះគឺជា បញ្ហារបស់រដ្ឋាភិបាល និយោជក ឬរបស់អ្នកទាំងពីរ? តើគេតម្រូវឱ្យមានវិភាគទានសម្រាប់តម្លៃទាំងនេះមួយផ្នែកពីអ្នកធ្វើការងារ ពីសមាជិកនៃសហព័ន្ធសហជីព? អ្នកណាគ្រប់គ្រងសុខុមាលភាពសង្គម? តើសុខុមាលភាពសង្គម ត្រូវធានាដោយរដ្ឋាភិបាល ឬដោយគណៈកម្មការគ្រប់គ្រង ដែលជ្រើសរើសតាមបែបលិទ្ធិប្រជាធិបតេយ្យ? អ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងករណីមាន ជម្លោះផ្សេងៗ សាលាជម្រះក្តី ចាត់តាំងចៅក្រម ។ល។ ប្រព័ន្ធតុលាការនៃប្រទេសត្រូវតែឯករាជ្យ អំពីរដ្ឋាភិបាល និងសាកល្បងទប់ទល់បំបាត់អំពើពុករលួយ និងអំពើរំលោភបំពាន តើប្រទេសគ្រប់គ្រងភាពក្រីក្រដូចម្តេច?

តើគេអនុវត្តវិធានការដូចម្តេចក្នុងការគិតគូដល់ប្រជាជនក្រីក្រ ដល់អ្នកងាយរងគ្រោះ ដល់អ្នកដល់អ្នកជំងឺ ដល់មនុស្សវ័យចំណាស់ និងដល់អ្នកគ្មានស្បៀងអាហារ?

តើអ្នកណាកំណត់យកប្រជាជនក្រីក្រដែលមានលក្ខណៈកំណត់សក្តិសមទទួលយកនូវការគាំទ្រ និងជំនួយជាប្រាក់កាសដែលពួកគេត្រូវការ?

តើបញ្ហាទាំងនេះតែងពាក់ព័ន្ធសហជីពឬ? តើគេគ្រាន់តែត្រូវធ្វើអន្តរាគមន៍ប៉ុណ្ណោះ កាលណារឿងនោះទាក់ទងនឹងសមាជិករបស់ខ្លួន។

- **ការធ្វើផែនការសេដ្ឋកិច្ច និងពាណិជ្ជកម្ម** ចូរយើងស្រមៃមើលឃើញថារដ្ឋាភិបាល សន្យាចំពោះនិយោជក បើគេបើករោងចក្រក្នុងតំបន់ជនបទពួកគេ អាចប្រព្រឹត្ត ដោយគ្មានអន្តរាគមន៍ របស់

សហព័ន្ធពាណិជ្ជកម្ម និងចំណាយប្រាក់បៀវត្សរ៍ត្បិតត្បៀតទៅឱ្យអ្នកធ្វើការងារ។ ចូរយើងស្រមៃថា ធ្វើមិនដឹង មិនឮអំពីពលកម្មកុមារ តើសហជីពត្រូវធ្វើដូចម្តេច? តើគេរ៉ាប់រងដូចម្តេចដើម្បីភ្ជាប់ ទៅនឹងពាណិជ្ជកម្ម ប្រសិនបើបញ្ហាទាំងនោះសំខាន់សម្រាប់អភិវឌ្ឍប្រទេសមួយ ត្រូវបានគេ ប្រើប្រាស់ ដើម្បីយកជនបទក្រីក្រជាឧបករណ៍ការងារក្នុងលក្ខខណ្ឌលំបាក ហើយទទួលប្រាក់ បៀវត្សយ៉ាងទាប? តើគេរ៉ាប់រងដូចម្តេចដើម្បីឱ្យកុមារត្រូវបានគេការពារក្នុងកាលៈទេសៈ យ៉ាង នេះ? តើច្បាប់ដូចគ្នានេះត្រូវតែអនុវត្តនៅតាមក្រុមហ៊ុនបរទេស ដែលចូលមកក្នុងប្រទេស បាន ឬទេ? តើលក្ខខណ្ឌនៃការងារអ្វីខ្លះ សម្រាប់ពលករនៃក្រុមហ៊ុនបរទេស? តើសហជីពកំពុងតែរៀបចំពលករ និងការពារផលប្រយោជន៍របស់ពួកគេ ឬទេ? តើសហជីពចូលរួមធ្វើសេចក្តីសម្រេចចិត្តទៅតាម ផែនការសេដ្ឋកិច្ច និងទៅតាមបញ្ហានៃពាណិជ្ជកម្មបទេ? នេះគឺជាកម្លាំងជំរុញឬទេ? តើសេចក្តីសម្រេចចិត្តទាំងនេះត្រូវតែទុកឱ្យរដ្ឋាភិបាល និងនិយោជក ឬឱ្យក្រុមដទៃទៀត ត្រូវចូលរួម ទាក់ទងដែរ ហេតុអ្វី?

សិទ្ធិរបស់ពលករ និងសិទ្ធិមនុស្ស គឺជាបញ្ហាសំខាន់សម្រាប់សហជីពដោយហេតុថា ប្រសិទ្ធភាពនៃសិទ្ធិទាំងនេះសហជីពត្រូវមានវត្តមានដើម្បីធ្វើអ្វីៗសារៈសំខាន់នៃសហជីពតម្រូវឱ្យការការពារសិទ្ធិរបស់អ្នកធ្វើការងារ។ ដូច្នេះសហព័ន្ធសហជីពពាណិជកម្មត្រូវរ៉ាប់រងឱ្យអ្នកធ្វើការងារម្នាក់ៗ មនុស្សម្នាក់ៗ និងកុមារម្នាក់ៗ អាចទទួលបានផលពីសិទ្ធិជាមូលដ្ឋានរបស់មនុស្សដែលត្រូវបានប្រកាស ជាសកលរួចមកហើយ។ សហជីពចង់ឱ្យសមាជិករបស់ខ្លួនបានទទួលផលប្រយោជន៍ពីសិទ្ធិសហជីពរបស់គេ និងត្រូវបានការពារ។ រីឯសិទ្ធិអ្នកដទៃទៀតត្រូវបានទទួលផលចំណុចណា? តើមិនមែនរដ្ឋាភិបាលទេឬដែលញ៉ាំងយើងគ្រប់គ្នា គោរពសិទ្ធិមនុស្ស? ប្រសិនបើរដ្ឋាភិបាលមិនធ្វើរឿងនោះទេ តើអ្នកណានឹងការពារ និងជួយឧបត្ថម្ភ អ្នកដែលមិនអាចការពារខ្លួនបានដូចជា កុមារទាំងឡាយជាដើម? អ្នកណាឃ្លាំមើលរដ្ឋាភិបាល និងនិយោជក ដើម្បីធានាឱ្យមានការអនុវត្តទៅដោយត្រឹមត្រូវ? តើយន្តការណាត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីធានាឱ្យមានការគោរពសិទ្ធិមនុស្សឱ្យបានត្រឹមត្រូវ?

## គណៈកម្មការដឹកនាំ និងគ្រប់គ្រង

| | |
|---|---|
| ១_លោក ភុង ហនស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តួច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គួលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គីមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទីម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការរៀបរៀង និងចងក្រង

| | |
|---|---|
| ១_លោក ភុង ហនស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តួច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គួលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គីមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទីម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៦_លោក ឡុង សុផាត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការបកប្រែ

| | | | |
|---|---|---|---|
| ១_លោកស្រី កង សុថាវី | ប្រធានការិយាល័យក្រោយអក្ខរកម្ម | ២_លោកស្រី តុប ប៊ុនថា | ប្រធានការិយាល័យអក្ខរកម្ម |
| ៣_លោក ព៉ៅម ភីណារ៉េត | អនុប្រធានការិយាល័យរដ្ឋបាល | ៤_លោក តេះ ដារី | អនុប្រធានការិ.ផែនការនិងគ្រប់គ្រងទិន្នន័យ |
| ៥_លោក ជិន និវត្តន៍ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_លោកស្រី ទី វត្តី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោក ភូ យន់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៨_លោកស្រី ស្រ៊ុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៩_កញ្ញា អ៊ុក ធារី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ១០_លោក គ្រួច លក្ខិណា | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ១១_លោកស្រី លី ខេង | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការផ្ទៀងផ្ទាត់

| | | | |
|---|---|---|---|
| ១_លោក សំ ចាន់ទិត | អនុប្រធានការិយាល័យអក្ខរកម្ម | ២_លោក រង់ សូវង្ស | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក ឈុំ ច័ន្ទមុនីរ៉េត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៤_លោកស្រី ជា សុផល | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក កែវ គង់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_កញ្ញា ម៉ៅ ផល្លី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោកស្រី ស្រ៊ុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការឌីហ្សាញ និងកុំព្យូទ័រ

| | |
|---|---|
| ១_លោក ឈិន វិត | ប្រធានការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ២_លោក ពេជ្រ និពន្ធ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៣_លោកស្រី ឈុំ សោភ័ណ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៤_លោកស្រី សួច ផាន់ណា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៥_លោកស្រី ទី រ៉ាដា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៦_កញ្ញា សន សុម៉ាលី | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |

# បញ្ឈប់ពលកម្មកុមារ

# Stop Child Labour

**Supporting Children's Rights through Education, the Arts and the Media (SCREAM)**


**សូមថ្លែងអំណរគុណ**

- ដល់អង្គការពលកម្មអន្តរជាតិ (ILO) ដែលបានជួយឧបត្ថម្ភថវិកា ក្នុងការបកប្រែ រៀបរៀង និងបោះពុម្ព។
- ចំពោះលោក **មេនណាឌី ប៉ូល យូសេហ្វ** ប្រធានទីប្រឹក្សាបច្ចេកទេស និងលោក **ថេង ឆវីរិទ្ធ** មន្ត្រីកម្មវិធីនៃ *អង្គការពលកម្មអន្តរជាតិ* (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) គាំទ្រកម្មវិធីពេលវេលាកំណត់ (TBP SP) នៅកម្ពុជាដែលបានជួយផ្តល់ការណែនាំផ្សេងៗ និងការគាំទ្របច្ចេកទេស ព្រមទាំងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ដើម្បី **ស្គ្រីម** (SCREAM) កើតមានឡើងនៅកម្ពុជា។

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមសេចក្តីប្រកាស
លេខ 101 អយក ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦



នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ : លេខ ១៦៨ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង១
ខណ្ឌ ចំការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : **(០២៣ ៧២៦ ៥៦៣ / ២១៩ ២៥៨**

**Email** : **nfe@camnet.com.kh**



ISBN-9789995088217